**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economic

# សារណាបញ្ចប់ការសិក្សា

# អំណាចមេបាក្នុងរឿងលែងលះ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភាឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **គីម ដាលីន**

**សៅ វឌ្ឍនា**

សាស្ត្រាចារ្យណែនាំ

**គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គីម ដាលីន** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី២២ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៨ ដល់ឆ្នាំសិក្សា២០២២។

សូមសម្តែងនូវកតញ្ញូតាធម៌រលឹកដឹងគុណដ៏ជ្រាលជ្រៅ ចំពោះលោកទាំងពីរដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ និង បានខិតខំចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់មិនថាក្នុងកាលៈទេសៈណា ពេលណានោះទេ លោកទាំងពីរតែងតែពុះពាររាល់ឧបសគ្គ ការនឿយហត់ទាំងឡាយដើម្បីកូន ថែមទាំងជួយផ្តល់នូវកម្លាំងចិត្ត ព្រមទាំងធនធានគ្រប់បែបយ៉ាងដល់រូបខ្ញុំឱ្យទទួលបានការសិក្សា តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សា ទាំងនេះសុទ្ធសឹងតែជាគុណបំណាច់ដ៏ធំធេងរបស់លោកទាំងពីរ។ ដោយសារតែការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើឱ្យកូនមិនប្រព្រឹត្តអំពើណាដែលសង្គមស្អប់ខ្ពើម ហើយកូនប្រតិបត្តិតែអំពើសុចរិតទៀងត្រង់ និងបានតម្រង់ទិសឱ្យកូនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ ដែលមានចំណេះដឹងជាធនធានល្អមួយរូបនៅក្នុងសង្គម។

ខ្ញុំបាទឈ្មោះ **សៅ វឌ្ឍនា** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២២ ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៨ ដល់ឆ្នាំសិក្សា២០២២។

សូមសម្តែងនូវកតញ្ញូតាធម៌រលឹកដឹងគុណដ៏ជ្រាលជ្រៅ ចំពោះលោកទាំងពីរដែលបានផ្តល់កំណើតដល់រូបនាងខ្ញុំ និង បានខិតខំចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់មិនថាក្នុងកាលៈទេសៈណា ពេលណានោះទេ លោកទាំងពីរតែងតែពុះពាររាល់ឧបសគ្គ ការនឿយហត់ទាំងឡាយដើម្បីកូន ថែមទាំងជួយផ្តល់នូវកម្លាំងចិត្ត ព្រមទាំងធនធានគ្រប់បែបយ៉ាងដល់រូបខ្ញុំឱ្យទទួលបានការសិក្សា តាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សា ទាំងនេះសុទ្ធសឹងតែជាគុណបំណាច់ដ៏ធំធេងរបស់លោកទាំងពីរ។ ដោយសារតែការយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើឱ្យកូនមិនប្រព្រឹត្តអំពើណាដែលសង្គមស្អប់ខ្ពើម ហើយកូនប្រតិបត្តិតែអំពើសុចរិតទៀងត្រង់ និងបានតម្រង់ទិសឱ្យកូនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ ដែលមានចំណេះដឹងជាធនធានល្អមួយរូបនៅក្នុងសង្គម។

## សូមថ្លែងអំណរគុណចំពោះ

ឯកឧត្តម **លុយ ចន្ទ្រា** ដែលលោកជាសាកលវិទ្យាធិការនៃ**សាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលរៀន និងផ្តល់ជាកន្លែងដ៏កក់ក្តៅសម្រាប់ការសិក្សារៀនសូត្រ ក៏ដូចជាស្រាវជ្រាវ និងសូមអរគុណចំពោះ លោក/លោកស្រីថ្នាក់ដឹកនាំ សាស្រ្តាចារ្យនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ ដែលបានផ្តល់ចំណេះដឹងគ្រប់បែបយ៉ាង ព្រមទាំងយកចិត្តទុកដាក់បង្រៀនយើងខ្ញុំដោយមិនគិតនឿយហត់និងតែងតែផ្តល់

ដំបូន្មានល្អៗដល់ពួកខ្ញុំ តាំងពីចូលរៀនថ្នាក់មហាវិទ្យាល័យដំបូងរហូតដល់ចប់មហាវិទ្យាល័យ លោក/លោកស្រី គឺជាឪពុកម្ដាយទីពីរដែលតែងតែនៅជិតប្រឹក្សាយោបល់ឱ្យដល់ពួកខ្ញុំជានិច្ច ដើម្បីឱ្យក្លាយជាធនធានដ៏ល្អ សម្រាប់សង្គមជាតិនាពេលអនាគត។

ជាពិសេស លោកសាស្ត្រាចារ្យ **គង់ សុភ័ក្ត្រ** ដែលជាសាស្ត្រាចារ្យណែនាំក្នុងកិច្ចការសារណាមួយនេះ ដែលលោក បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ បង្ហាត់បង្ហាញអស់ពីកម្លាំងចិត្ត កម្លាំងកាយ កែតម្រូវ ផ្ដល់ជាអនុសាសន៍ និងជួយសម្របសម្រួលដល់កិច្ចការសារណាមួយនេះឱ្យបញ្ចប់ទៅបានដោយរលូន។

ម្យ៉ាងវិញទៀតក៏សូមថ្លែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូដែលបានជួយត្រួតពិនិត្យខ្លឹមសារអត្ថបទនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំដើម្បីឱ្យសារណានេះកាន់តែប្រសើរឡើង។

ជាចុងក្រោយយើងខ្ញុំទាំងពីរអ្នក សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ក្នុងលោកថែរក្សាការពារ និងប្រសិទ្ធពរជ័យជូនដល់អ្នកមានគុណទាំងពីរ និងសូមគោរពជូនពរដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី និងលោកគ្រូ អ្នកគ្រូ ព្រមទាំងមជ្ឈដ្ឋានទូទៅដែលបាននឹងកំពុងអានអត្ថបទនេះ សូមជួបតែសេចក្តីសុខសេចក្តីចម្រើន និងសុភមង្គលជានិរន្តរ៍ ព្រមទាំងជួបប្រទះសម្បត្តិទាំង៣ប្រការ គឺទី១ សម្បត្តិមនុស្ស ទី២ សម្បត្តិទេវតា និងទី៣ សម្បត្តិព្រះនិពាន្ត កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ (បួន) ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកសាធារណៈរួចមក យើងខ្ញុំទាំងពីរបានទទួលនូវ ចំណេះដឹងជាច្រើន លើមុខវិជ្ជាទាំងអស់នោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ មកដល់ពួកយើងខ្ញុំ។ កត្តានៃការជួយជ្រោមជ្រែង និងការយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យពួកយើងខ្ញុំទាំងពីរ អាចឈានមកដល់ការចងក្រងឯកសារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការរៀបចំសារណានេះឡើង ក្នុងគោលដៅដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២២ និងដើម្បីជាការចូលរួមចំណែកក្នុងសង្គម។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរ យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសប្រធានបទមួយ ដែលទាក់ទងនឹងផ្នែកនីតិឯកជនដែលមានចំណងជើងថា៖ ការកំណត់អំណាចមេបាក្នុងរឿងលែងលះ។ ការជ្រើសរើសប្រធាននេះឡើងមក គឺដើម្បីអោយបុគ្គលគ្រប់រូបដែលបានអាន បានយល់ដឹងកាន់តែច្បាស់អំពីអំណាចមេបា ព្រោះនឹងដឹងថានៅពេលមានការលែងលះ អំណាចមេបានឹងមានរូបភាពបែបណា នីតិវិធីច្បាប់ធ្វើការកំណត់បែបណា ហើយបន្ទាប់ពីមានការកំណត់អំពីអ្នកមានអំណាចមេបាហើយ ថាតើអ្នកដែលមានអំណាចមេបា និងអ្នកដែលគ្មានសិទ្ធិអំណាចមេបាត្រូវមានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះចំពោះកូនបន្ទាប់ពីមានការលែងលះ។ ហើយអំណាចមេបានៅពេលលែងលះនេះផងដែរ មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណាមួយនេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងចង់ស្វែងយល់បន្ថែមទាក់ទង អំណាចមេបានៅពេលដែលមានការលែងលះដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ហើយឯកសារសារណាមួយនេះនឹងត្រូវបានរក្សាទុកជាស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីជាភាពងាយស្រួយក្នុងសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមលើអត្ថបទដែលទាក់ទងនឹងប្រធានបទមួយនេះ។

ជាចុងក្រោយយើងខ្ញុំក៏សូមអភ័យទោសទុកជាមុនផងដែរ ប្រសិនបើមានចំណុចខ្វះខាតណាមួយទៅលើពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ ឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា ហើយយើងខ្ញុំនឹងទទួលនូវការរិះគន់លើអត្ថបទនេះ ពីសំណាក់អ្នកអាន ដើម្បីជាការស្ថាបនាឱ្យកាន់តែប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណគតិយុត្ត

**ផ្នែកទី១ ភាពជាអ្នកមានអំណាចមេបា**........ ៣

**១.១. និយមន័យ**........ ៣

**១.២ លក្ខខណ្ឌ** ........ ៣

១.២.១. អំណាចមេបារួម ........ ៣

ក. ករណីដែលឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍........ ៣

ខ. ករណីមានការបង្កើតរបបស្មុំកូន........ ៤

១.២.២. អំណាចមេបាទោល ........ ៥

ក. ករណីមានការលែងលះ ........ ៥

ខ. ករណីលែងលះគ្នាមុនកំណើតកូន........ ៥

គ. ករណីឪពុកម្តាយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ........ ៥

**ផ្នែកទី២ ការលែងលះ** ........ ៦

**២.១. មូលហេតុនៃការលែងលះ** ........ ៦

**២.២. ប្រភេទនៃការលែងលះ** ........ ៧

២.២.១. ការលែងលះតាមការព្រមព្រៀង ........ ៧

ក. លក្ខខណ្ឌ ........ ៧

ខ. ការដាក់ពាក្យសុំលែងលះ........ ៨

២.២.២. ការលែងលះតាមផ្លូវបណ្តឹង ........ ៨

ក. លក្ខខណ្ឌ ........ ៩

ខ. ការដាក់ពាក្យបណ្តឹង........ ៩

**២.៣. អានុភាពនៃការលែងលះ**........ ៩

២.៣.១. អានុភាពចំពោះសហព័ទ្ធ ........ ១០

២.៣.២. អានុភាពលើទ្រព្យសម្បត្តិ ........ ១០
២.៣.៣. អានុភាពលើកូន ........ ១១

## ជំពូកទី២

## ការកំណត់អំណាចមេបា

**ផ្នែកទី១ ការកំណត់អំណាចមេបានៅក្នុងពេលលែងលះ** ........ ១២
**១.១. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមពាក្យសុំ** ........ ១២
១.១.១. ការកំណត់អំណាចមេបាក្រៅនីតិវិធីតុលាការ ........ ១២
១.១.២. ការកំណត់អំណាចមេបាក្នុងនីតិវិធីតុលាការ ........ ១៣
**២.២. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមពាក្យបណ្ដឹង** ........ ១៣
២.២.១. ការកំណត់អំណាចមេបាតាមការទាមទាររបស់ដើមចោទ ........ ១៣
២.២.២. ការកំណត់អំណាចមេបាតាមឆន្ទានុសិទ្ធិរបស់តុលាការ ........ ១៤
ក. ស្ថានភាពរបស់ឪពុក ឬម្ដាយ ........ ១៤
ខ. ស្ថានភាពរបស់កូន ........ ១៦
**ផ្នែកទី២ អានុភាពនៃសិទ្ធិអំណាចមេបា** ........ ១៦
**២.១. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា** ........ ១៦
២.១.១. សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន ........ ១៦
ក. ការបីបាច់ថែរក្សារូបកាយកូន ........ ១៧
ខ. ការអប់រំកូន ........ ១៧
គ. ការដាក់ទណ្ឌកម្មកូន ........ ១៧
ឃ. ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម ........ ១៧
ង. ការទាមទារឱ្យប្រគល់កូន ........ ១៨
២.១.២. ការគ្រប់គ្រងទ្រព្យសម្បត្តិនិងការតំណាង ........ ១៨
២.១.៣. ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាចំពោះអំពើអនីត្យានុកូលរបស់កូន ... ២០
២.១.៤. ការផ្ដល់ការយល់ព្រមចំពោះទំនាក់ទំនងឋានៈបុគ្គល ........ ២០
**២.២. សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងអ្នកពុំមានសិទ្ធិអំណាចមេបា** ........ ២១
២.២.១. ការចួលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ........ ២១

២.២.២. ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន ..........................................២២
២.២.៣. ការពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន ..........................................២២

## ជំពូកទី៣

## ការបាត់បង់សិទ្ធិអំណាចមេបា

**ផ្នែកទី១ ការផ្លាស់ប្តូរអ្នកមានអំណាចមេបា** ..........................................២៤
**១.១. ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា** ..........................................២៤
១.១.១. ការព្យួរ ឬការដកហូតអំណាចមេបា..........................................២៤
១.១.២. នីតិវិធីនៃការព្យួរ ឬការដកហូតអំណាចមេបា..........................................២៥
**១.២. ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា**..........................................២៦
១.២.១. មូលហេតុនៃការលាឈប់ពីអ្នកមានអំណាចមេបា..........................................២៦
១.២.២. នីតិវិធីនៃការលាឈប់ ..........................................២៧
**១.៣. ករណីអ្នកមានអំណាចមេបាទទួលមរណភាព** ..........................................២៧
**ផ្នែកទី២ ការបញ្ចប់អំណាចមេបា**..........................................២៨
**២.១. ការដល់នីតិភាពរបស់កូន**..........................................២៨
**២.២. អានុភាពនៃការបញ្ចប់អំណាចមេបា** ..........................................២៩
**២.៣. ការអនុវត្តនៃការបញ្ចប់អំណាចមេបា** ..........................................៣០
**សេចក្តីសន្និដ្ឋាន**..........................................៣១
**អនុសាសន៍**..........................................៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមរស់នៅប្រចាំថ្ងៃ កាលបើបុគ្គលពីរនាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយបានបង្កើតកូនដែលជាចំណងដៃអាពាហ៍ពិពាហ៍ ប្រាកដណាស់ពួកគេទាំងពីរជាអ្នកមានសិទ្ធិអំណាចមេបាចំពោះកូនដោយសហការ គឺមានករណីយកិច្ចក្នុងការមើលថែ គ្រប់គ្រង ចិញ្ចឹមបីបាច់ អប់រំកូន ជាអាទិ៍។ ចំពោះ ស្ថានភាពដែលឪពុកម្ដាយរស់នៅជាមួយគ្នា មិនជាបញ្ហាធ្ងន់អ្វីទេទាក់ទងនឹងសិទ្ធិអំណាចមេបា ប៉ុន្តែ ប្រសិនបើឪពុកម្ដាយ បានបែកបាក់ចំណងអាពាហ៍ពិពាហ៍នឹងគ្នា កូនជាអ្នករងគ្រោះ ព្រោះថានៅក្នុងទិដ្ឋភាពច្បាប់ នៃប្រទេសកម្ពុជានៅពេលមានការលែងលះ អំណាចមេបាចំពោះកូនត្រូវបានបែងចែកឱ្យឪពុក ឬ ម្ដាយតែម្ខាងជាអ្នកមានសិទ្ធិអំណាចមេបា ដែលជាការអនុវត្តអំណាចមេបាទោល។ បន្ទាប់ពីមានការបែងចែក អំពីអ្នកមានអំណាចមេបាតាមរយៈដីកាសម្រេច ឬ សាលក្រមរួចរាល់ នាំឱ្យកូនដែលជាអនីតិជនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុក ឬម្ដាយដែលមានសិទ្ធិ។ ចំណែកឯ ឪពុក ឬ ម្ដាយដែលគ្មានសិទ្ធិអំណាចមេបា មិនមែនមានន័យថាត្រូវតែមិនមានសិទ្ធិអ្វីទាំងអស់ចំពោះកូននោះទេ ដែលក្នុងនោះអ្នកគ្មានសិទ្ធិអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចមួយចំនួនទាក់ទងនឹងកូន ក្នុងការជួយផ្ដល់អាហារកាតព្វកិច្ច ការប្រាស្រ័យទាក់ទងកូន ដឹងអំពីស្ថានភាពរបស់កូនតាមអ្វីដែលអ្នកទាំងពីរបានធ្វើការព្រមព្រៀងគ្នា និងបានធ្វើការកំណត់ក្នុងសេចក្ដីសម្រេច។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

នៅពេលមានវិវាទការលែងលះកើតឡើង តើនីតិវិធីក្នុងដោះស្រាយអ្នកមានអំណាចមេបាប្រព្រឹត្តទៅយ៉ាងដូចម្ដេច? តើតុលាការមានយុទ្ធសាស្ត្របែបណាក្នុងសម្រេចអ្នកមានសិទ្ធិអំណាចមេបាទៅលើកូន?

បន្ទាប់ពីសេចក្ដីសម្រេចរបស់តុលាការបានបញ្ចប់ជាស្ថាពរ អ្នកដែលមានសិទ្ធិអំណាចមេបា និងអ្នកដែលគ្មានសិទ្ធិអំណាចមេបាមានសិទ្ធិនិងករណីយកិច្ចអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីចូលរួមចំណែកបង្កើននូវចំណេះដឹង និងព្រមទាំងដើម្បីសិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីការកំណត់អំណាចមេបា និងដំណើរការនីតិវិធីនានាដែលកើតឡើងក្នុងការលែងលះ។ មួយវិញទៀតការស្រាវជ្រាវនេះ ក៏បានធ្វើឱ្យពួកខ្ញុំទាំងពីរបានយល់ដឹងអំពីមូលហេតុ និងនីតិវិធីរបស់តុលាការក្នុងសម្រេចលើសិទ្ធិអំណាចមេបាមួយកម្រិតទៀតផងដែរ។ មិនតែប៉ុណ្ណោះ វាក៏ជាឯកសារមួយសម្រាប់តម្កល់ទុកក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយបានធ្វើការសិក្សាជាបន្ទាប់បន្សំ។ តែយ៉ាងណាចំពោះគោលបំណងគ្រឹះ និងគោលបំណងចម្បងនៃការសិក្សា គឺផ្ដោតយ៉ាងសំខាន់ទៅលើការកំណត់អំណាចមេបានៅក្នុងរឿងលែងលះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទខាងលើនេះ មានដែនកំណត់ស្ថិតក្រោម រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦។ ក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរ គឺផ្តោតសំខាន់ទៅលើមូលហេតុ និង នីតិវិធីនៃការបែងចែកអំណាចមេបានៅពេលមានការលែងលះប៉ុណ្ណោះ។ កាលដែលបានកំណត់អំពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវដែលបានរៀបរាប់ខាងលើនេះ បានធ្វើឱ្យយើកាន់តែមានភាពងាយស្រួលក្នុងការស្រាវជ្រាវ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវអត្ថបទមួយនេះ បានផ្តល់សារៈសំខាន់ជាច្រើនដល់ប្រជាពលរដ្ឋទូទៅ និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋានទាំងអស់ដែលបានអាន បានយល់កាន់តែច្បាស់ និងកាន់តែស៊ីជម្រៅទាក់ទងអំណាចមេបាក្នុងរឿងលែងលះ។ ម្យ៉ាង ក៏អាចទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវ ព្រមទាំងសិស្សនិស្សិតទាំងអស់ដែលមានបំណងចង់ស្វែងយល់ពីប្រធានបទនេះ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ ការកំណត់អំណាចក្នុងរឿងលែងលះ យើងខ្ញុំបានធ្វើការបែងចែកជា ០៣ (បី)ជំពូកមានដូចខាងក្រោមៈ

ជំពូកទី១ សញ្ញាណគតិយុត្ត

ជំពូកទី២ ការកំណត់អំណាចមេបា

ជំពូកទី៣ ការបាត់បង់សិទ្ធិអំណាចមេបា

# ជំពូកទី១
# សញ្ញាណគតិយុត្ត

# ជំពូកទី១

# សញ្ញាណគតិយុត្ត

## ផ្នែកទី១ ភាពជាអ្នកមានអំណាចមេបា

ជាទូទៅ អ្នកដែលមានអំណាចមេបាទៅលើអនីតិជនមានតែឪពុកម្ដាយបង្កើតតែប៉ុណ្ណោះ ដែលគាត់មានករណីយកិច្ចក្នុងការចិញ្ចឹមបីបាច់ និងគ្រប់គ្រងកូន។ ប៉ុន្តែ ក្នុងករណីខ្លះអ្នកដែលមានសិទ្ធិអំណាចមេបាក៏អាចមិនមែនជាឪពុកម្ដាយបង្កើតដែរ ពោលគឺអាចជាបុគ្គលផ្សេងទៀត ដូចជាឪពុកម្ដាយចិញ្ចឹម ក៏អាចមានសិទ្ធិអំណាចមេបាមកលើកូនដែលជាអនីតិជនបានដូចគ្នាផងដែរ។

### ១.១. និយមន័យ

ដោយយោងតាមមាត្រា១០៣៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំណាចមេបាគឺសំដៅដល់អ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់ថែរក្សារូបរាងកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ ដូចនេះមានន័យថា អំណាចមេបា គឺផ្ដើមចេញពីទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន ដែលឪពុកម្ដាយមានករណីយកិច្ច ក្នុងការបីបាច់ថែរក្សា និងគ្រប់គ្រងកូន។

### ១.២. លក្ខខណ្ឌ

ដោយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា អំណាចមេបាត្រូវបានប្រគល់ឱ្យឪពុកម្ដាយចំពោះកូន ដែលជាអនីតិជន ហើយកាលដែលផ្ដល់ឱ្យទាំងឪពុកនិងម្ដាយបែបនេះ ហៅថា "*អំណាចមេបារួម*"។ ប៉ុន្តែចំពោះ ករណីមួយចំនួនអំណាចមេបាត្រូវបានផ្ដល់ឱ្យតែឪពុក ឬម្ដាយតែម្នាក់ប៉ុណ្ណោះ ដែលមានអំណាចមេបាចំពោះកូន ដែលហៅថា "*អំណាចមេបាទោល*"។ ដូច្នេះអំណាចមេបាត្រូវបានបែងចែកជាពីរ គឺ អំណាចមេបារួម និងអំណាចមេបាទោល។

#### ១.២.១. អំណាចមេបារួម

#### ក. ករណីដែលឪពុកម្ដាយមានចំណងអាពាហ៍ពិពាហ៍

ឪពុកម្ដាយមានចំណងអាពាហ៍ពិពាហ៍ សំដៅដល់ឪពុកម្ដាយដែលបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ឪពុកម្ដាយមានចំណងអាពាហ៍ពិពាហ៍ ត្រូវអនុវត្ត អំណាចមេបាចំពោះកូនជាអនីតិជនដោយសហការគ្នា។[1] មានន័យថា រាល់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន រាល់ការចិញ្ចឹមបីបាច់ថែរក្សាកូន ឬ សកម្មភាពតំណាងឱ្យកូន គឺត្រូវធ្វើឡើងដោយមានការសម្រេចចិត្តទាំងពីរនាក់ ទាំងឪពុក និងម្ដាយ មិនមែនសម្រេចចិត្តតែម្ដាយ ឬ ឪពុកតែម្នាក់ទេ។ ប៉ុន្តែ នៅក្នុងស្ថានភាព ដែលឪពុក ឬ ម្ដាយម្នាក់ណា មិនអាចអនុវត្តលើអំណាចមេបា

[1] មាត្រា១០៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បាននោះនាំឱ្យការសម្រេច ត្រូវបានធ្វើឡើងតាមការសម្រេចចិត្តរបស់ឪពុក ឬ ម្តាយតែម្នាក់បាន បើទោះបីជាស្ថិតក្នុងអំណាចមេបារួមក៏ដោយ។[2] ជាក់ស្តែងក្នុងករណី "ក" ជាអនីតិជន អាយុ១០ឆ្នាំ[3] ដែលស្ថិតក្រោមអំណាចមេបារបស់ "ខ" ជាឪពុក និង "គ" ជាម្តាយ តែ "ខ" ដែលជាឪពុក ត្រូវបានជួបគ្រោះថ្នាក់ចរាចរណ៍កាលពី ៣ ឆ្នាំមុនធ្វើឱ្យគាត់ពិការគេងនៅនឹងមួយកន្លែង និងប៉ះពាល់ត្រង់ផ្នែកក្បាលខ្លាំងធ្វើឱ្យគាត់មានស្មារតីខ្សោយ បាត់បង់ការយល់ដឹង។ ថ្មីៗនេះ ជីតារបស់ "ក" បានធ្វើប្រទានកម្មឡានមួយគ្រឿងទៅឱ្យ "ក" ដែលជាចៅច្បង ដោយ "ក" មិនចង់ទុកឡាននោះចោល ដោយសារតែខ្លួនមិនទាន់អាចប្រើប្រាស់ ឬអាចបើកឡាននោះដោយខ្លួនឯងបាន ក៏មានបំណងចង់ជួលឡានដែលជា ទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យតតិយជនម្នាក់ទៀត តែដោយ "ក" ជាអនីតិជនមិនអាចធ្វើសកម្មភាព ក្នុងការធ្វើកិច្ចសន្យាដោយខ្លួនឯងបាននោះទេ[4] ដោយសកម្មភាពក្នុងកិច្ចសន្យានេះត្រូវធ្វើឡើង ដោយមានការតំណាងពីអ្នកមានសិទ្ធិអំណាចមេបារបស់ខ្លួន។ ក្នុងករណីដែលកូនចង់បង្កើតកិច្ចសន្យាជួលរថយន្តនោះ បើទោះបីជាស្ថិតក្នុងអំណាចមេបារួមក៏ដោយ គឺ "គ" ដែលជាម្តាយ គាត់អាចធ្វើការសម្រេចតែម្នាក់ឯង និងតំណាងឱ្យកូនតែម្នាក់ឯងបាន ដោយមិនចាំបាច់មានការចូលរួមពីឪពុក ព្រោះឪពុករបស់ "ក" មានបញ្ហាខាងផ្នែកសារតីក្នុងការយល់ដឹង មិនអាចធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិ នឹងមើលថែទាំអនីតិជនបាន ដែលជាហេតុធ្វើឱ្យគាត់មិនអាចអនុវត្តអំណាចមេបាក្នុងការតំណាងបាន។

### ខ. ករណីមានការបង្កើតរបបសុំកូន

ដោយការសុំកូន គឺជាការសុំកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងជាការបង្កើតនូវទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម ដូចទៅនឹងឪពុកម្តាយនិងកូនបង្កើតដែរ។ ការសុំកូនអាចធ្វើឡើងតាម០២ (ពីរ) រូបភាពគឺ សុំកូនធម្មតា និងសុំកូនពេញលេញ។ សុំកូនធម្មតា ជាការបង្កើតទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមដែលត្រូវយកមកចិញ្ចឹមបីបាច់ដូចជាកូនរបស់ខ្លួន តែការសុំកូនធម្មតាមិនត្រូវបានផ្តាច់នូវទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនឡើយ ពោលក្នុងករណីមានការបង្កើតរបបសុំកូនអំណាចមេបាត្រូវបានផ្តល់ឱ្យឪពុកម្តាយចិញ្ចឹម មិនថា សុំកូនពេញលេញ និងសុំកូនធម្មតា។ ដោយសុំកូនពេញលេញអាចបង្កើតបានតែចំពោះអនីតិជន តែប៉ុណ្ណោះ ហើយចំពោះអនីតិជនដែលមានអាយុកំណត់ក្រោម ៨ (ប្រាំបី) ឆ្នាំ ហើយអ្នកដែលចង់សុំកូនអ្នកផ្សេង យកមកចិញ្ចឹមតាមប្រព័ន្ធកូនសុំពេញលេញ គឺត្រូវតែជាប្តីប្រពន្ធដែលមានចុះបញ្ជីអាពាហ៍ពិពាហ៍ (មានសំបុត្រអាពាហ៍ពិពាហ៍ ឬអតាស៊ីវិល)។ ប្រសិនបើ ករណីដែលប្តីប្រពន្ធនោះមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេ តុលាការក៏មិនសម្រេចឱ្យមានការបង្កើតរបបសុំកូនពេញលេញដែរ។ ចំណែក

[2] មាត្រា១០៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[3] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[4] មាត្រា១៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ស្មុំកូនធម្មតាវិញ គឺយើងអាចធ្វើការបង្កើតស្មុំកូនបានទាំងនីតិជន និងអនីតិជន។ ដោយសម្រាប់អនីតិជន គឺឪពុកម្តាយចិញ្ចឹមជាអ្នកមានអំណាចមេបាមកលើអនីតិជននោះ។

### ១.២.២. អំណាចមេបាទោល

#### ក. ករណីមានការលែងលះ

នៅពេលប្តីប្រពន្ធលែងលះគ្នា អំណាចមេបា ត្រូវកំណត់ដោយការព្រមព្រៀងរវាងប្តីប្រពន្ធដែលជាឪពុកម្តាយ ប៉ុន្តែប្រសិនបើមិនអាចកំណត់ដោយការព្រមព្រៀងទេ តុលាការត្រូវកំណត់ឪពុក ឬ ម្តាយណាម្ខាងជាអ្នកមានអំណាចមេបាចំពោះកូនដែលជាអនីតិជន។[5] ដែលនេះ ជាការអនុវត្តអំណាចមេបាទោល។

#### ខ. ករណីលែងលះគ្នាមុនកំណើតកូន

ការលែងលះមុនកំណើតកូន សំដៅដល់ករណីដែលការលែងលះនាពេលកូននៅក្នុងពោះម្តាយនៅឡើយ ពោលកូននៅជាគភ៌នៅឡើយ។ ក្នុងករណីនេះ សិទ្ធិអំណាចមេបាមកលើកូន ត្រូវក្លាយជាសិទ្ធិរបស់ម្តាយដោយស្វ័យប្រវត្តិ។ ប៉ុន្តែ ក្នុងករណីដែលឪពុកចង់បាន អំណាចមេបាចំពោះកូនដែលបានកើតមក ឪពុកអាចពិភាក្សាជាមួយម្តាយបានដើម្បីទទួលបានអំណាចមេបា តែបើម្តាយមិនព្រមទេ ឪពុកត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ក្នុងការសម្រេចថាឪពុកអាចទទួលបានសិទ្ធិជាអ្នកមានអំណាចមេបាចំពោះកូន ឬក៏អត់។[6]

#### គ. ករណីឪពុកម្តាយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍

ក្នុងករណីដែលឪពុកម្តាយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ អំណាចមេបាត្រូវធ្លាក់ទៅលើម្តាយដែលជាអ្នកបង្កើតកូននោះដោយស្វ័យប្រវត្តិ ប៉ុន្តែប្រសិនបើឪពុក របស់កូនធ្វើការទទួលស្គាល់ ហើយមានការយល់ព្រមពីម្តាយ នោះឪពុកត្រូវទទួលបាននូវអំណាចមេបាទោល។ តែ ប្រសិនបើគាត់មិនអាចទទួលបានអំណាចមេបាតាមការព្រមព្រៀងទេ គាត់អាចដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការទាមទារ ហើយតុលាការនឹងធ្វើការសម្រេច។[7]

ម្យ៉ាងទៀត បើទោះបីជាឪពុកម្តាយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ ក្នុងករណីដែលគាត់មានកូនជាអនីតិជន ដែលត្រូវបានទទួលស្គាល់កូនតាមសំបុត្រកំណើត បន្ទាប់មកគាត់បានចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលស្ថានភាពបែបនេះក៏អាចទទួលបាននូវអំណាចមេបាដោយសហការគ្នាផងដែរ។[8]

[5]មាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[6]មាត្រា១០៣៧ កថាខណ្ឌទី២ និងទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[7] មាត្រា១០៣៨ កថាខណ្ឌទី១ ទី២ និងទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[8]មាត្រា១០៣៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ផ្នែកទី២ ការលែងលះ

អាពាហ៍ពិពាហ៍កើតចេញពីការស្ម័គ្រចិត្តរបស់មនុស្សពីរនាក់ ដែលបានកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងពីរនាក់គឺប្តី និងប្រពន្ធ។ ជាមួយគ្នានេះដែរ ការរំលាយក៏មិនអាចប្រព្រឹត្តិទៅដោយសេរីនោះទេ ពោលគឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌដ៏តឹងរឹង និង មានការចូលអន្តរាគមន៍ពីស្ថាប័នរដ្ឋ(តុលាការ)។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ប្រសិនបើភាគីណាមួយយល់ឃើញថា ជីវិតអាពាហ៍ពិពាហ៍របស់ខ្លួន ពុំអាចបន្តរស់នៅជាមួយគ្នាតទៅទៀតបាន ដោយសារភាពមិនចុះសម្រុងគ្នា ជាហេតុបណ្តាលឱ្យគ្រួសារបែកបាក់នាំឱ្យអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។

ការលែងលះ ជាការរំលាយទំនាក់ទំនងប្តី និង ប្រពន្ធតាមផ្លូវតុលាការ។ ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ គឺផ្តាច់រាល់ទំនាក់ទំនងគតិយុត្ត ដែលមានអានុភាពនាំឱ្យប្តី ឬប្រពន្ធ រួចផុតពីករណីយកិច្ចរួមរស់ជាមួយគ្នា សហការគ្នា និងជួយសង្គ្រោះគ្នាទៅវិញទៅមក រួមទាំងករណីយកិច្ចស្មោះត្រង់ផងដែរ។[9]

ជាក់ស្តែងនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មិនបានធ្វើការកំណត់និយមន័យការលែងលះឱ្យបានជាក់លាក់ ដែលចូលជាធរមាននោះឡើយ។ ប៉ុន្តែជាទូទៅ ការលែងលះគឺសំដៅទៅលើការផ្តាច់ ឬ ការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ រវាងប្តី និងប្រពន្ធ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

## ២.១. មូលហេតុនៃការលែងលះ

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានកំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល និងភាពស្មើគ្នារវាងបុរស នារី និងសិទ្ធិលើទ្រព្យសម្បត្តិជាដើម។[10] នេះសបញ្ជាក់យ៉ាងច្បាស់ថា ក្រមរដ្ឋប្បវេណីបានគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលដែលរួមមានដូចជា ការរៀបអាពាហ៍ពិពាហ៍ ឬ ការលែងលះគឺសុទ្ធសឹងតែជាការព្រមព្រៀង ដែលកើតចេញពីឆន្ទៈរបស់បុគ្គលម្នាក់ៗ ដោយមិនមានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។ ដូចនេះ ប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមានការរកាំរកូស ដែលជាហេតុនាំឱ្យមានការបែកបាក់ តុលាការអាចសម្រេចឱ្យមានការលែងលះដោយការព្រមព្រៀង ប្រសិនបើតុលាការយល់ឃើញថាភាគីសងខាងពិតជាមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ប្រសិនបើ ភាគីមិនអាចមានការព្រមព្រៀងលែងលះនោះទេ ការលែងលះអាចធ្វើទៅបានតាមរយៈការដាក់ពាក្យបណ្តឹងទៅកាន់តុលាការ។[11]

---

[9] មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10] មាត្រា ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[11] មាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយយោងតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មូលហេតុនៃការលែងលះគ្នាបានបែងចែកជាពីរ គឺ មូលហេតុជាក់លាក់ និងមូលហេតុមិនជាក់លាក់។

រាល់មូលហេតុដែលមានភាពច្បាស់លាស់ទៅលើករណីនីមួយៗ ត្រូវបានកំណត់ថាជាមូលហេតុជាក់លាក់។ ដោយមូលហេតុទាំងនោះមានបញ្ញត្តិនៅក្នុងមាត្រា៩៧៨ កថាខណ្ឌទី១ ចំណុច ក ដល់ចំណុច ឃ នៃក្រមរដ្ឋប្បវេណីដូចជា៖

- ការប្រព្រឹត្តអំពើផិតក្បត់
- ការបោះបង់ចោលសហព័ទ្ធដែលគ្មានមូលហេតុត្រឹមត្រូវ
- ការដែលមិនដឹងថា សហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ
- សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ។

ក្រៅអំពីមូលហេតុកំណត់ជាក់លាក់នីមួយៗខាងលើ ការលែងលះ អាចប្រព្រឹត្តិទៅបានក្នុងករណីផ្សេងទៀតដែលជាមូលហេតុមិនជាក់លាក់ គឺសំដៅទៅលើទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិទានវិញបាន។[12]

## ២.២. ប្រភេទនៃការលែងលះ

ការលែងលះនៅកម្ពុជា អាចធ្វើឡើងតាមពីររបៀប គឺ ការលែងលះដោយការព្រមព្រៀង (២.២.១) និង ការលែងលះតាមបណ្តឹង (២.២.២) ។

### ២.២.១. ការលែងលះតាមការព្រមព្រៀង

នៅពេលដែលភាគីនៃអាពាហ៍ពិពាហ៍ បានព្រមព្រៀងគ្នាក្នុងការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ដោយមិនមានទំនាស់លើការបែងចែកសិទ្ធិ និងកាតព្វកិច្ចផ្សេងៗក្រោយពេលលែងលះ ត្រូវចាត់ទុកជាការលែងលះតាមការព្រមព្រៀង។

#### ក. លក្ខខណ្ឌ

តាមរយៈឆន្ទៈព្រមព្រៀងរបស់ភាគី ភាពចាំបាច់នៃមូលហេតុមិនបានតម្រូវទេ ពោលឱ្យតែភាគីប្តី និងប្រពន្ធបង្ហាញឆន្ទៈស្ម័គ្រចិត្តលែងលះគ្នា គឺអាចដាក់ពាក្យសុំទៅតុលាការបាន ហើយដំណើរការនីតិវិធីដោះស្រាយត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ តុលាការនឹងសម្រេចអនុញ្ញាតឱ្យលែងលះ ប្រសិនបើតុលាការពិនិត្យឃើញថា ការព្រមព្រៀងកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគី។ ផ្ទុយទៅវិញ បើតុលាការយល់ឃើញថា ភាគីមិនមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដូចជាការលែងលះក្លែងក្លាយ តុលាការនឹងសម្រេចមិនអនុញ្ញាតឱ្យលែងលះ។

[12] មាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជាមួយគ្នានេះដែរ ស្ថិតក្នុងលក្ខខណ្ឌនៃការបញ្ចប់អានុភាពនៃអាពាហ៍ពិពាហ៍តាមការព្រមព្រៀងភាគីប្តី និង ប្រពន្ធដែលមានកូនមិនទាន់ពេញវ័យ ការកំណត់អំពីអ្នកមានអំណាចមេបាជាចំណុចដែលសំខាន់។ ដូចនេះ ដើម្បីអាចលែងលះតាមការព្រមព្រៀង លុះត្រាតែមានការព្រមព្រៀងអំពីអំណាចមេបា បើមិនដូច្នោះទេភាគីមិន អាចដាក់ពាក្យលែងលះតាមការព្រមព្រៀងបានទេ។

**ខ. ការដាក់ពាក្យសុំលែងលះ**

ចំពោះការដាក់ពាក្យសុំ លែងលះតាមការព្រមព្រៀង ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ការលែងលះ ត្រូវធ្វើឡើងដោយពាក្យសុំ ហើយតុលាការសម្រេចសេចក្តីក្រោមរូបភាពជាដីកាសម្រេច។ រាល់ពេលមានការលែងលះដោយការព្រមព្រៀង ភាគីដែលមានបំណងត្រូវដាក់ពាក្យសុំលែងលះទៅតុលាការខាងលំនៅឋានរបស់ប្តី ឬ ប្រពន្ធ។[13] ពាក្យសុំអាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ក្នុងករណីពាក្យសុំធ្វើជាលាយលក្ខណ៍អក្សរ[14] ហើយក្នុងករណីពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខក្រឡាបញ្ជី។ អ្នកដាក់ពាក្យសុំ ត្រូវដាក់ពាក្យសុំ ត្រូវបង់ពន្ធចំនួន៥០០០ (ប្រាំពាន់) រៀល។[15] ជាមួយគ្នានេះដែរ នៅក្នុងពាក្យសុំលែងលះ ភាគីអាចធ្វើការទាមទារបន្ទាប់បន្សំរួមមានការទាមទារឱ្យបែងចែកទ្រព្យសម្បត្តិ ការទាមទារសោហ៊ុយអាពាហ៍ពិពាហ៍ និងការកំណត់អំពីសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនអាចធ្វើឡើងនៅក្នុងពាក្យសុំលែងលះ។

តុលាការអាចសម្រេចសេចក្តីយកអង្គហេតុដែលមិនបានអះអាង ដោយអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីបាន និងក្នុងករណីចាំបាច់តុលាការនឹងស្រាវជ្រាវអង្គហេតុ និងធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ។ ការសម្រេចសេចក្តីត្រូវធ្វើឡើងដោយដីកាសម្រេច ដីកាសម្រេចនេះ អាចប្តឹងជំទាស់បាន[16] ហើយដីការសម្រេចនេះមានអានុភាពអនុវត្តដោយបង្ខំ។

**២.២.២. ការលែងលះតាមផ្លូវបណ្តឹង**

ការលែងលះតាមផ្លូវបណ្តឹង ត្រូវប្រព្រឹត្តិឡើងតាមតែរយៈការទាមទាររបស់ភាគីតែម្ខាងប៉ុណ្ណោះ នៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុដែលកំណត់ដោយច្បាប់។ ការលែងលះតាមផ្លូវបណ្តឹង មានភាពស្មុគស្មាញជាងការលែងលះតាមរយៈការព្រមព្រៀង ព្រោះភាគីទាមទារឱ្យលែងលះ ត្រូវទទួលបន្ទុកបញ្ជាក់អង្គហេតុនីមួយៗ ដែលជាមូលហេតុនៃការទាមទារ។

[13] មាត្រា ៤ ឧបសម្ព័ន្ធទី៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[14] មាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[15] មាត្រា ២២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[16] មាត្រា ៣៩ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

**ក. លក្ខខណ្ឌ**

ជាគោលការណ៍ តុលាការត្រូវសម្រេចឱ្យលែងលះ ក្នុងករណីដែលមូលហេតុមានបញ្ញត្តិតាមផ្លូវច្បាប់ត្រូវបានទទួលស្គាល់។ ដោយយោងតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មូលហេតុនៃការលែងលះគ្នាបានបែងចែកជាពីរ គឺ មូលហេតុជាក់លាក់ និងមូលហេតុមិនជាក់លាក់។

នៅក្នុងបណ្តឹងលែងលះ ដើមចោទអាចធ្វើការទាមទារចម្បង និងការទាមទារផ្សេងៗទៀតហៅថា ការទាមទារបន្ទាប់បន្សំ។ ចំពោះការទាមទារចម្បង គឺតម្រូវឱ្យធ្វើការអះអាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ តុលាការនឹងសម្រេចឱ្យលែងលះ ប្រសិនបើមូលហេតុសមស្របនឹងទទួលស្គាល់តាមច្បាប់ ប៉ុន្តែទោះបីជាមូលហេតុនៃការលែងលះ ត្រូវបានទទួលស្គាល់ក៏ដោយ តុលាការនឹងមិនសម្រេចអនុញ្ញាតឱ្យលែងលះ កាលបើការលែងលះបណ្តាលឱ្យជីវភាពរបស់សហព័ទ្ធ ឬកូនលំបាក និងការទាមទារផ្ទុយនឹងភាពសុចរិត។ ចំណែកឯការទាមទារផ្សេងទៀត អាចធ្វើឡើងតាមការទាមទារបែងចែកទ្រព្យសម្បត្តិរួម កំណត់អំណាចមេបាលើកូន ឬជាការទាមទារសំណងការខូចខាត និងការទាមទារអាហារកាតព្វកិច្ចជាដើម។

**ខ. ការដាក់ពាក្យបណ្តឹងលែងលះ**

អាពាហ៍ពិពាហ៍ ជាចំណងដែលបង្កើតឡើងដោយការស្ម័គ្រចិត្តក៏ពិតមែន ប៉ុន្តែនៅពេលដែលភាគីលែងចង់រួមរស់ជាមួយគ្នាពោលគឺ ចង់រួចផុតពីករណីយកិច្ចជាប្តីប្រពន្ធដោយការលែងលះ ត្រូវធ្វើឡើងតាមផ្លូវតុលាការ។ ដោយហេតុនេះហើយភាគីដែលមានបំណងលែងលះ ត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ប៉ុន្តែភាគីក៏អាចដាក់ពាក្យបណ្តឹងលែងលះទៅក្រុមប្រឹក្សាឃុំសង្កាត់ដែរ។[17] ពាក្យបណ្តឹងលែងលះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ[18] ដែលដើមចោទត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ចតុលាការ នៃលំនៅឋានរបស់ប្តី ឬ ប្រពន្ធ។ ដើមចោទត្រូវបង់ពន្ធដាក់ពាក្យបណ្តឹង ចំនួន៥៥០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។[19]

ការសម្រេចអំពីបណ្តឹងលែងលះ អនុវត្តដូចគ្នានឹងនីតិវិធីបណ្តឹងធម្មតាដែរ ពោលគឺតុលាការត្រូវកំណត់អំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកំណត់នូវចំណុចវិវាទ និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងចេញសាលក្រម។

## ២.៣. អានុភាពនៃការលែងលះ

ការលែងលះមានអានុភាពផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធ នៅពេលដែលសេចក្តីសម្រេចអំពីការលែងលះបានចូលជាស្ថាពរ។ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ នៅពេលដែល អំឡុងពេល

[17] មាត្រា ៩៨២ នៃក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[18] មាត្រា ៧៥ នៃក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[19] មាត្រា៦០ កថាខណ្ឌទី៣ និងមាត្រា៦១ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

នៃបណ្តឹងឧបាស្រ័យបានកន្លងផុត។ បើសេចក្តីសម្រេចនេះជាសាលក្រម អំឡុងពេលប្តឹងឧទ្ធរណ៍ គឺ០១ខែ គិតចាប់ដែលបានទទួលលិខិតសាលក្រម។ នៅក្នុងករណីដែលសេចក្តីសម្រេចនេះជា ដីកាសម្រេច គឺត្រូវប្តឹងជំទាស់ក្នុងអំឡុងពេល ២ សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងពីដីកាសម្រេចនេះ។[20] ដូច្នេះ នៅពេលដែលផុតអំឡុងពេលដូចបានបញ្ជាក់ជូនខាងលើនេះ សេចក្តីសម្រេចអំពីការលែងលះនឹងចូលជាស្ថាពរ។

### ២.៣.១. អានុភាពចំពោះសហព័ទ្ធ

ការលែងលះនាំឱ្យសហព័ទ្ធរួចផុតពីកាតព្វកិច្ចទាំងឡាយ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍។ ក៏ប៉ុន្តែទន្ទឹមនឹងនេះ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារអនុញ្ញាតឱ្យសហព័ទ្ធម្ខាង ទាមទារអាហារកិច្ចពីសហព័ទ្ធម្ខាងទៀតបាន កាលបើមានលក្ខខណ្ឌសមស្របដូចខាងក្រោម៖[21]

- អតីតសហព័ទ្ធ ដែលអ្នកស្នើសុំនោះគ្មានកំហុសក្នុងការលែងលះគ្នា។
- អតីតសហព័ទ្ធមានការខ្វះខាត បានសេចក្តីថា ភាគីគ្មានកំហុសពុំមានទ្រព្យសម្បត្តិ ឬ មុខរបរជាក់លាក់សម្រាប់ចិញ្ចឹមជីវិតខ្លួន។ គួរកត់សម្គាល់ថា ការខ្វះខាតនេះ មិនសំដៅតែលើការខ្វះខាតម្ហូបអាហារសម្រាប់បរិភោគប៉ុណ្ណោះទេ គឺសំដៅទៅលើអ្វីដែលជាធាតុចាំបាច់ សម្រាប់ឱ្យជនដែលមានសិទ្ធិទទួលអាហារកិច្ច អាចរស់នៅដោយសមស្រប ដូចជាអាចមានជម្រក សម្លៀកបំពាក់ លទ្ធភាពទិញថ្នាំសង្កូវជាដើម។

ជាធម្មតា អតីតសហព័ទ្ធដែលត្រូវផ្តល់អាហារកិច្ច ត្រូវមានលទ្ធភាពផ្តល់អាហារកិច្ចនោះ។ ក្នុងករណីនេះចៅក្រមពិនិត្យទៅលើប្រាក់បៀវត្ស លទ្ធភាពនៃការរកប្រាក់ចំណូល អាយុ សុខភាពរបស់ជននោះដើម្បីកំណត់ពីអាហារកិច្ចដែលត្រូវបង់។ ក៏ប៉ុន្តែ ប្រសិនបើ ជនដែលត្រូវទទួលអាហារកិច្ចរៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត ជននោះលែងមានសិទ្ធិទទួលអាហារកិច្ចនោះទៀតហើយ។

ចំណែក ប្តី ឬប្រពន្ធដែលបានប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនរៀបអាពាហ៍ពិពាហ៍បាន ឬអាចប្រើនាមត្រកូលដែលបាននៅពេលលែងលះគ្នាក៏បាន។[22]

### ២.៣.២. អានុភាពលើទ្រព្យសម្បត្តិ

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ត្រូវធ្វើទៅតាមគោលការណ៍យល់ព្រមរបស់ភាគីទាំងសងខាង។ ផ្ទុយទៅវិញបើភាគីពុំអាចពិភាក្សាបានទេ គឺត្រូវតែធ្វើការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកទៅតាមចំណុចនីមួយៗ ដូចខាងក្រោម៖

[20] មាត្រា៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

[21] មាត្រា៧៦ និងមាត្រា៧៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍

[22] មាត្រា៩០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- សហព័ទ្ធម្នាក់ៗ ត្រូវទទួលបាននៅទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។
- បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធម្នាក់ៗ ត្រូវទទួលបាននៅ ១ ភាគ ២ នៃទ្រព្យរួម។ ក៏ប៉ុន្តែ បើមានករណីពិសេស និងមានការទាមទារ របស់ប្តី ឬ ប្រពន្ធណាមួយ តុលាការក៏អាចធ្វើការបែងចែកទ្រព្យសម្បត្តិរួម ដោយធ្វើការពិចារណាទៅលើស្ថានភាពផ្សេងដូចជាៈ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យអំឡុងពេលរៀបអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីមួយៗ និងផលប្រយោជន៍របស់កូន ជាអាទិ៍។[23]

ផ្សេងពីនេះទៀត តុលាការក៏អាចសម្រេចឱ្យសហព័ទ្ធណាម្នាក់សងតម្លៃនៃទ្រព្យសម្បត្តិដោយឡែកដែលភាគីម្ខាងទៀតបានបំផ្លាញក្នុងអំឡុងពេលមានចំណងរៀបអាពាហ៍ពិពាហ៍បានដែរ។

### ២.៣.៣. អានុភាពលើកូន

នៅក្នុងករណីមានការលែងលះ តុលាការត្រូវតែកំណត់ពីអ្នកមានអំណាចមេបា ដោយឆន្ទានុសិទ្ធិពោលគឺទោះបីជាមិនមានពាក្យសុំពីភាគីក៏ដោយ។[24]

ជាគោលការណ៍ ការកំណត់ត្រូវតែធ្វើឡើងតាមការពិភាក្សារបស់សហព័ទ្ធ។ ប៉ុន្តែ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។[25] ម៉្យាងវិញទៀត ប្រសិនបើមានការលែងលះ នៅពេលមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាច។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាលើកូនបាន តាមរយៈការពិភាក្សារវាងឪពុកម្តាយ។ ចំពោះភាគីដែលមិនមានអំណាចមេបាលើកូន គាត់មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

[23] មាត្រា៩៨០ កថាខណ្ឌទី២ ចំណុចខ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[24] មាត្រា២២ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០

[25] មាត្រា១០៣៧ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី២
# ការកំណត់អំណាចមេបា

# ជំពូកទី២

# ការកំណត់អំណាចមេបា

## ផ្នែកទី១ ការកំណត់អំណាចមេបានៅក្នុងពេលលែងលះ

ក្នុងប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា ការកំណត់អំណាចមេបា តុលាការត្រូវតែធ្វើការកំណត់ បើទោះបីជាគ្មានការស្នើសុំពីភាគីក៏ដោយ។ តែ ប្រសិនបើមានការព្រមព្រៀងគ្នាកំណត់យកអ្នកណាម្នាក់ជាអ្នកមានអំណាចមេបាចំពោះកូន តុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀង។ ប៉ុន្តែ បើភាគីមិនបានធ្វើការព្រមព្រៀងទេ តុលាការនឹងធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ ដោយផ្អែកលើឧត្តមប្រយោជន៍របស់កូនជាធំ។

### ១.១. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមពាក្យសុំ

ចំណុចនៃការព្រមព្រៀងអំពីអ្នកមានអំណាចមេបាចំពោះកូន មានលក្ខណៈដូចគ្នានឹងចំណុចព្រមព្រៀងអំពីទ្រព្យដែរ ព្រោះថា បើភាគីមានការព្រមព្រៀង នាំឱ្យគ្មានចំណុចវិវាទ ដូច្នេះ តុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀងនោះ។ ដែលអំណាចមេបា អាចធ្វើការព្រមព្រៀងក្រៅតុលាការ ឬ ក្នុងនីតិវិធីតុលាការក៏បាន ដែលមានអានុភាពចងតុលាការ។ ដោយនៅក្នុងករណីលែងលះតាមពាក្យសុំ ភាគីអាចធ្វើការកំណត់អ្នកមានអំណាចមេបាក្រៅនីតិវិធីតុលាការ (១.១.១) និងការកំណត់អ្នកមានអំណាចមេបាក្នុងនីតិវិធីតុលាការ (១.១.២)។

#### ១.១.១. ការកំណត់អ្នកមានអំណាចមេបាក្រៅនីតិវិធីតុលាការ

ដើម្បីឱ្យការលែងលះតាមពាក្យសុំដំណើរការទៅបាន ក្នុងករណីដែលភាគីទាំងពីរមានកូនជាអនីតិជន ចាំបាច់ត្រូវតែកំណត់អំពីអ្នកមានអំណាចមេបាចំពោះកូនជាមុនសិន។ ដោយហេតុថា នៅរាល់ពេលផ្តាច់ចំណងអាពាហ៍ពិពាហ៍ អំណាចមេបាលើកូនមិនអាចប្រព្រឹត្តទៅដោយសហការគ្នាបានទៀតទេ ដូច្នេះប្រាកដណាស់កូនគឺជាអ្នកដែលត្រូវរងគ្រោះ។ ដូច្នេះហើយ ទើបការសម្រេចអំពីអ្នកអំណាចមេបានៅក្នុងពាក្យសុំពិតជាមានសារៈសំខាន់ ដែលបានផ្តល់នូវផលប្រយោជន៍យ៉ាងខ្លាំងទៅដល់កូនជាអនីតិជន។

កិច្ចព្រមព្រៀងកំណត់អ្នកមានអំណាចមេបានៅក្រៅនីតិវិធីតុលាការ គឺគូភាគីនៃពាក្យសុំលែងលះអាចធ្វើការព្រមព្រៀងគ្នាតាមរយៈកិច្ចព្រមព្រៀងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរបាន។ ដោយការព្រមព្រៀងជាលាយលក្ខណ៍អក្សរក្រៅនីតិវិធីតុលាការ មានខ្លឹមសារព្រមព្រៀងគ្នាលើចំណុចអំណាចមេបា ដែលត្រូវមានការចូលរួមយ៉ាងសំខាន់ពីភាគីប្តី និងប្រពន្ធ។ កិច្ចព្រមព្រៀងមានលក្ខណៈជាក់លាក់មួយ និងច្បាស់លាស់ ដែលស្តែងចេញពីឆន្ទៈពិតប្រាកដរបស់គូភាគី។ ការព្រមព្រៀងដែលកើតចេញពីឆន្ទៈរបស់ភាគីទាំងពីរ គឺមានគោលបំណងដើម្បីស្នើសុំឱ្យតុលាការធ្វើការកំណត់អំពីអ្នកមានអំណាចមេបាតាមការព្រមព្រៀង។ ជាក់ស្តែង បើមានការព្រមព្រៀងគ្នានៅក្រៅនីតិវិធីតុលាការ ដោយបានព្រមព្រៀងគ្នាថាឱ្យប្រពន្ធជាអ្នកមានអំណាចមេបាចំពោះកូន

ដូច្នេះនៅពេលដែលដាក់មកតុលាការ យើងអាចស្នើសុំឱ្យតុលាការកំណត់តាមអ្វីដែលយើងបានព្រមព្រៀងគ្នានោះនៅក្នុងសេចក្តីសម្រេចបញ្ចប់តុលាការនឹងធ្វើការសម្រេចទៅតាមអ្វីដែលភាគីបានព្រមព្រៀងគ្នា។

### ១.១.២. ការកំណត់អ្នកមានអំណាចមេបាក្នុងនីតិវិធីតុលាការ

ក្នុងការលែងលះតាមពាក្យសុំ ក្រៅអំពីការកំណត់អំណាចមេបាចំពោះកូនដែលជាអនីតិជនក្រៅនីតិវិធីតុលាការ ក៏អាចធ្វើការកំណត់ក្នុងនីតិវិធីបានដែរ ដោយភាគីនៃពាក្យសុំធ្វើការព្រមព្រៀងគ្នាបានដែលមានការកំណត់សរសេរនៅក្នុងពាក្យសុំនោះតែម្តង ដើម្បីសុំឱ្យតុលាការធ្វើការសម្រេចតាមអ្វីដែលសហព័ទ្ធបានព្រមព្រៀង។ ជាក់ស្តែងក្នុងនីតិវិធីនៃកិច្ចសាកសួរ បើការសាកសួរបញ្ជាក់ថាគូភាគីពិតជាមានការព្រមព្រៀងគ្នាដោយពិតប្រាកដដូចដែលមានសរសេរក្នុងពាក្យសុំមែន តុលាការនឹងធ្វើការកំណត់អំពីអ្នកមានអំណាចមេបាតាមការព្រមព្រៀង តាមរយៈសេចក្តីសម្រេចបញ្ចប់ ឬ ដីកាសម្រេច។

ប្រសិនបើភាគីនៃពាក្យសុំ និងភាគីម្ខាងទៀត ចង់ធ្វើការលែងលះតាមការព្រមព្រៀង តែភាគីដែលបានដាក់ពាក្យសុំ បានឱ្យធ្វើការកំណត់យកខ្លួនដែលជាអ្នកដាក់ពាក្យសុំ ជាអ្នកមានអំណាចមេបាចំពោះកូន ប៉ុន្តែមិនមានការកំណត់ជាក់លាក់ណាមួយអំពីការព្រមព្រៀងចំពោះអំណាចមេបាបាននោះទេ ពោលគឺគូភាគីមានវិវាទដែលភាគីម្ខាងទៀតក៏ចង់ក្លាយជាអ្នកមានអំណាចមេបាចំពោះកូនដែរ។ នាំឱ្យភាគីទាំងពីរមានវិវាទអំពីកូន មិនអាចព្រមព្រៀងគ្នាបានទេ ដូច្នេះតុលាការនឹងធ្វើការលើកចោលពាក្យសុំដោយដីកាសម្រេច មានន័យថាតុលាការមិនអាចឱ្យលែងលះតាមការព្រមព្រៀងបានទេ បើភាគីមិនបានព្រមព្រៀងគ្នាអំពីអ្នកមានអំណាចមេបាចំពោះកូនបាន។

## ២.២. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមពាក្យបណ្តឹង

ការកំណត់អំណាចមេបាតាមរយៈពាក្យបណ្តឹង អាចធ្វើការកំណត់អ្នកមានសិទ្ធិអំណាចមេបាទៅតាមពីររូបភាពគឺ (២.២.១) កំណត់អំណាចមេបាតាមការទាមទាររបស់ដើមចោទ និង (២.២.២) កំណត់អំណាចមេបាតាមឆន្ទានុសិទ្ធិរបស់តុលាការ។

### ២.២.១. ការកំណត់អំណាចមេបាតាមការទាមទាររបស់ដើមចោទ

ការទាមទារអំណាចមេបាទោលចំពោះកូន ត្រូវធ្វើឡើងស្របពេលជាមួយនឹងការលែងលះ មានន័យថាទាល់តែមានការលែងលះ ទើបភាគីគាត់អាចធ្វើការទាមទារអំពីអ្នកមានអំណាចមេបាបាន ដែលជាការទាមទារបន្ទាប់បន្សំ ពីការទាមទារចម្បងនៃការលែងលះ។ ហើយ បើទោះជាមានបណ្តឹងលែងលះក៏ដោយ បើការលែងលះមិនអាចដំណើរទៅបាន ឬមិនបានសម្រេច ដោយហេតុថាមិនមានមូលហេតុសមស្រប និងមិនមានមូលហេតុណាមួយដូចដែលមានបញ្ញត្តិក្នុងច្បាប់អំពីការលែងលះទេ ដូចជា ការផិតក្បត់ បោះបង់សហព័ទ្ធដោយគ្មានមូលហេតុជាអាទិ៍ នាំឱ្យការទាមទារបន្ទាប់បន្សំក៏មិនអាចកើតមានដែរ។

នៅក្នុងការធ្វើបណ្ដឹងលែងលះ បើដើមចោទបានធ្វើការទាមទារកំណត់យកខ្លួនជាអ្នកមានសិទ្ធិអំណាចមេបាដោយលើកយកមូលហេតុសមស្របណាមួយនៃការទាមទារ ហើយ បើដំណើរការនៃនីតិវិធីបើកការសាកសួរលើចំណុចដែលជាការទាមទាររបស់ដើមចោទ ឃើញថាភាគីម្ខាងទៀតមិនមានឆន្ទៈក្នុងការទាមទារធ្វើជាអ្នកមានអំណាចមេបា ឬក៏បោះបង់នូវសិទ្ធិ មានន័យថា ភាគីចុងចម្លើយនឹងធ្វើការព្រមព្រៀង តាមរយៈសេចក្ដីថ្លែងការយល់ព្រមចំពោះការទាមទារអំណាចមេបារបស់ដើមចោទ ដែលនាំឱ្យចំណុចនៃការទាមទារអំណាចមេបាមិនមែនជាចំណុចវិវាទតទៅទៀតទេ។ ម្យ៉ាងវាជាចំណុចទាមទារបន្ទាប់បន្សំ ដូច្នេះតុលាការមិនមានវិសាលភាពក្នុងការវិនិច្ឆ័យតទៅទៀតឡើយ បើភាគីមានការព្រមព្រៀងគ្នាអំពីចំណុចអំណាចមេបា តុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀង។ ហើយសេចក្ដីសម្រេចរបស់តុលាការលើអ្នកមានសិទ្ធិអំណាចមេបាតាមការព្រមព្រៀងរបស់ភាគី និងត្រូវធ្វើឡើងតាមរយៈសាលក្រមនៃបណ្ដឹងលែងលះ។

### ២.២.២. ការកំណត់អំណាចមេបាតាមឆន្ទានុសិទ្ធិរបស់តុលាការ

ក្នុងករណីឪពុកម្ដាយមិនអាចពិភាក្សា ឬ ពិភាក្សាមិនបានសម្រេច អំពីការកំណត់អ្នកមានអំណាចមេបា តុលាការត្រូវកំណត់យកឪពុក ឬ ម្ដាយ ជាអ្នកមានអំណាចមេបា ដោយពិចារណាអំពីផលប្រយោជន៍របស់កូន។[26] ក្នុងនេះដែរ ដំណើរការនៃការពិចារណាលើសិទ្ធិអ្នកមានអំណាចមេបា ត្រូវបានចូលរួមពីតំណាងអយ្យការក្នុងការបញ្ចេញយោបល់ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ក្នុងការការពារផលប្រយោជន៍សាធារណៈ[27] ព្រោះថា បណ្ដឹងលែងលះជាបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ហើយសាលក្រមមានវិសាលភាពគ្របដណ្ដប់លើសពីភាគីនៃបណ្ដឹង។

ជាគោលការណ៍តុលាការនឹងធ្វើការសម្រេច ផ្អែកលើមូលដ្ឋានវិនិច្ឆ័យ ដោយគិតអំពីផលប្រយោជន៍របស់កូនជាធំ ដែលនឹងធ្វើការពិនិត្យស្ថានភាពរបស់ឪពុក ឬ ម្ដាយ និង ស្ថានភាពរបស់កូន។

#### ក. ស្ថានភាពរបស់ឪពុក ឬម្ដាយ

ជាទូទៅនៅពេលមានការលែងលះ តែងតែមានការទាមទារឱ្យកំណត់អំពីអ្នកមានអំណាចមេបាទៅលើកូន ប៉ុន្តែទោះជាយ៉ាងនោះក្ដីក៏តុលាការត្រូវវិនិច្ឆ័យឱ្យបានហ្មត់ចត់ទៅលើស្ថានភាពរបស់ឪពុកម្ដាយជាសំខាន់ព្រោះជាចំណុចដែលទាក់ទងទៅនឹងឧត្តមប្រយោជន៍របស់កូន។ ដូច្នេះក្នុងការពិនិត្យលើស្ថានភាពរបស់ឪពុកម្ដាយ តុលាការឈរលើចំណុចបីធំៗ ដែលជាគោលការណ៍ក្នុងការកំណត់សិទ្ធិអំណាចមេបាក្នុងរឿងលែងលះ។ តុលាការត្រូវធ្វើការសង្កេតលើសេដ្ឋកិច្ច (ការងារ មុខរបរ ប្រាក់ចំណូល) ថាតើឪពុក ឬម្ដាយណាម្ខាង ដែលមានការងារ និង ប្រាក់ចំណូលទៀងទាត់ ដើម្បីធានាដល់ការចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូន ព្រោះការចិញ្ចឹមថែរក្សា

---

[26] មាត្រា១០៣៧ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27] មាត្រា៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

កូន ជាចាំបាច់ត្រូវប្រើប្រាស់ថវិកាច្រើនក្នុងការផ្គត់ផ្គង់ក្នុងការរស់នៅប្រចាំថ្ងៃ។ ជាមួយគ្នានេះដែរ ឪពុកឬម្តាយត្រូវតែមានអាយុ និងសុខភាពល្អ ដែលអាចមើលថែបីបាច់ថែរក្សាកូន ព្រោះថាបើមានអាយុច្រើន ជរា មានជម្ងឺប្រចាំកាយ ឬអលទ្ធភាពក្នុងការគ្រប់គ្រងកូន នោះនឹងនាំឱ្យបង្កជាហានិភ័យដល់រូបកូនបន្ទាប់ពីធ្វើការលែងលះ។ ម្យ៉ាងវិញទៀត ក្តីស្រលាញ់ ភាពជិតស្និត និងមនោសញ្ចេតនាទៅលើកូន ក៏ជាចំណុចសំខាន់ដែលតុលាការត្រូវយកធ្វើការវិនិច្ឆ័យ ក្នុងការសម្រេចថាអ្នកណាអាចមានសិទ្ធិអំណាចមេបាគ្រប់គ្រងកូន តាមរយៈក្តីស្រលាញ់ពីសំណាក់ឪពុកម្តាយទៅលើកូន ដោយមូលហេតុថាជាការផ្តល់នូវសុភមង្គលដល់កូន បន្ទាប់ពីឪពុកម្តាយបានលែងលះគ្នា។

ករណីនៅពេលមានការលែងលះ ប្រសិនជាឪពុកម្តាយទាំងពីរសុទ្ធតែមានឆន្ទៈក្នុងការធ្វើជាអ្នកមានអំណាចមេបាចំពោះកូន នាំឱ្យកើតមាននូវចំណុចវិវាទ ហើយតុលាការនឹងធ្វើការវិនិច្ឆ័យលើចំណុចវិវាទដូចដែលបានរៀបរាប់ខាងលើ មានន័យថា បើសិនជាឪពុក ឬ ម្តាយណាម្ខាង គិតតែពីដើរផឹកស៊ី ឬ លេងល្បែងស៊ីសងគ្មានគិតគូរធ្វើការរកស៊ី គ្មានផ្ទះសម្បែងត្រឹមត្រូវ ឬ ក៏ធ្លាប់ប្រើអំពើហិង្សាលើកូន តុលាការនឹងមិនឱ្យឪពុក ឬម្តាយនោះ ជាអ្នកទទួលសិទ្ធិអ្នកអំណាចមេបាលើការគ្រប់គ្រងកូននោះទេ គឺប្រាកដជាប្រគល់ឱ្យម្ខាងទៀត ដែលមានការងារធ្វើច្បាស់លាស់ មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរិកសមរម្យ មានការយកចិត្តទុកដាក់ក្នុងការបីបាច់ថែរក្សាកូន។ ដោយតុលាការត្រូវថ្លឹងថ្លែងអំពីលទ្ធភាពរវាងឪពុកម្តាយ ដែលអាចផ្តល់ផលប្រយោជន៍ដល់កូនច្រើនជាងគេ ដើម្បីសម្រេចកំណត់ថាតើឪពុក ឬម្តាយខាងណាដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាអ្នកមានអំណាចមេបា។

ផ្ទុយទៅវិញ បើនៅពេលដែលដាក់ពាក្យបណ្តឹងលែងលះ ភាគីទាំងពីរបានដាក់ពាក្យលាឈប់ពីអ្នកមានសិទ្ធិអំណាចមេបាដោយភ្ជាប់ជាមួយពាក្យបណ្តឹង ប្រសិនបើតុលាការយល់ឃើញថាមូលហេតុដែលលើកឡើងនោះពិតជាមូលហេតុដែលមិនអាចជៀសបាន[28] នោះតុលាការនឹងធ្វើការអនុញ្ញាតលើការលាឈប់របស់ភាគីខាងលើ។ បន្ទាប់ពីបានធ្វើការសម្រេចអំពីការលាឈប់របស់អ្នកមានអំណាចមេបា នាំឱ្យមិនមានអ្នកអនុវត្តអំណាចមេបាលើកូន ដែលជាហេតុធ្វើឱ្យអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើម។[29] ដោយអាណាព្យាបាលត្រូវធ្វើឡើងតាមព្រមព្រៀងក្នុងញាតិ ៤ (បួន)ថ្នាក់ របស់អនីតិជន មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខមាលភាពកុមារ ឬ តំណាងអយ្យការបាន។[30]

ប៉ុន្តែ ប្រសិនបើ មូលហេតុនៃការលាឈប់ពីអ្នកមានសិទ្ធិអំណាចមេបា ពុំមានមូលហេតុសមស្របណា

[28] មាត្រា១០៥០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា១០៦៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា១០៦៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មួយដែលតុលាការមិនអនុញ្ញាតឱ្យមានការលាយឡំ នាំឱ្យតុលាការធ្វើការកំណត់យកភាគីណាម្នាក់ជាអ្នកមានសិទ្ធិអំណាចមេបា ដោយធ្វើការពិចារណាថា តើភាគីម្ខាងណាដែលផ្ដល់ផលប្រយោជន៍ចំពោះកូនជាង ទាក់ទងនឹងការទំនាក់ទំនងប្រចាំថ្ងៃ ការផ្ដល់នូវភាពស្និតស្នាលជាមួយកូន ភាពដែលអាចគ្រប់គ្រងកូនបាន មានធនធានគ្រាន់បើជាងជាអាទិ៍។ ចំណុចទាំងអស់នេះហើយ ដែលតុលាការនឹងធ្វើការសម្រេចឱ្យបានអំពីអ្នកមានអំណាចមេបា ព្រោះដើម្បីជាការធានាដល់ឧត្ដមប្រយោជន៍ដល់កុមារ ថាកុមារត្រូវតែមានអំណាចមេបា ទោះបីឪពុកម្ដាយបានលែងលះគ្នាក៏ដោយ។

#### ខ. ស្ថានភាពរបស់កូន

ទោះបីជាការពិចារណាលើស្ថានភាពរបស់ឪពុកម្ដាយសំខាន់ ក្នុងការកំណត់អ្នកមានសិទ្ធិអំណាចមេបាក៏ពិតមែន ក៏ប៉ុន្តែតុលាការត្រូវតែធ្វើការពិនិត្យលើស្ថានភាពរបស់កូនផងដែរ។ ដោយហេតុថាការទាមទារអំណាចមេបា ជាកម្មវត្ថុទាមទារនៅក្នុងបណ្ដឹងលែងលះ ដូច្នេះហើយការសម្រេចទៅឱ្យឪពុក ឬម្ដាយជាអ្នកគ្រប់គ្រងនិងថែរក្សាកូនជារឿងដ៏សំខាន់។ ជាបឋមតុលាការត្រូវពិនិត្យពិចារណាលើការលូតលាស់នៃសភាពរាងកាយរបស់កូន ដែលរួមមានការលូតលាស់ផ្នែកអវៈយវៈ ផ្នែកស្មារតី ជាអាទិ៍ ដោយត្រូវពិចារណាថាតើកូនស្ថិតជាទារក ឬវ័យកុមារ ដែលទាមទារឱ្យមានការនៅជិតស្និតមើលថែទាំរក្សាពីអ្នកជាឪពុក ឬម្ដាយ។ ទន្ទឹមនឹងនេះផងដែរ ការសាកសួរយោបល់អំពីអារម្មណ៍ផ្លូវចិត្តរបស់កូនទៅលើភាពជិតស្និតនៃចំណងរវាងឪពុកម្ដាយក៏ជាចំណុចសំខាន់មួយគួរឱ្យកត់សម្គាល់ផងដែរ ព្រោះជាកត្តាដែលអាចជះឥទ្ធិពលលើកូនទាំងរូបកាយ និងសតិអារម្មណ៍។ ឧបមាថាឪពុក ឬម្ដាយតែងតែបង្កជម្លោះក្នុងគ្រួសារដោយប្រើប្រាស់អំពើហិង្សា ពាក្យសម្ដីមិនសមរម្យ ឬមិនសូវបាននៅជិតបីបាច់រក្សាកូនកន្លងមកនោះ ប្រាកដណាស់ តុលាការនឹងមិនសម្រេចប្រគល់ឱ្យអំណាចមេបាឱ្យបុគ្គលនោះទេ ដោយប្រគល់ជូនភាគីដែលមានចំណងជិតស្និតជាមួយកូនជំនួស។

## ផ្នែកទី២ អានុភាពនៃសិទ្ធិអំណាចមេបា

### ២.១. សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា

នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តិករណីយកិច្ចមួយចំនួន ដែលតម្រូវឱ្យអ្នកដែលបានកំណត់ថាជាអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចដែលត្រូវគោរពតាមក្នុងអំឡុងពេលកំពុងអនុវត្តសិទ្ធិជាអ្នកមានអំណាចមេបាចំពោះកូន។

#### ២.១.១. សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន

ករណីយកិច្ចទាក់ទងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនត្រូវមានរហូតដល់កូនបានដល់នីតិភាព ដែលជាតួនាទីរបស់អ្នកមានអំណាចមេបា។ ករណីយកិច្ចទាក់ទងកូន រួមមាន ការបីបាច់ថែរក្សារូបរាងកាយកូន ការអប់រំកូន ការដាក់ទណ្ឌកម្មកូន និងការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម ជាដើម។

### ក. ការបីបាច់ថែរក្សារូបកាយកូន

រាល់សកម្មភាពទាំងឡាយដែលចាំបាច់សម្រាប់ការលូតលាស់ និងការការពារកូនដែលជាអនីតិជន ដោយរួមទាំងការផ្តល់ចំណីអាហារ សម្លៀកបំពាក់ ការស្នាក់នៅ ការផ្តល់ការថែទាំវេជ្ជសាស្ត្រ ការឱ្យកូនចូលរៀន និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងកូនដែលជាអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើស និងអំពើមិនត្រឹមត្រូវ។

### ខ. ការអប់រំកូន

អ្នកមានអំណាចមេបា ត្រូវធានាដល់ការជំរុញអភិវឌ្ឍន៍ខាងបញ្ញារបស់កូន និងការផ្តល់ឱ្យកូនទទួលបាននូវចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ដឹកនាំជីវិតនៅក្នុងសង្គម ហើយការអប់រំនេះផងដែរ គឺសំដៅទាំងការអប់រំក្នុងផ្ទះ និងសាលារៀន។

### គ. ការដាក់ទណ្ឌកម្មកូន

ក្នុងគោលបំណងដើម្បីអប់រំកូន អ្នកមានអំណាចមេបាគួរតែមានសិទ្ធិក្នុងការដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅពេលដែលកូនប្រព្រឹត្តអំពើប្រឆាំងនឹងសង្គម ឬ អំពើដែលពុំគប្បី ប៉ុន្តែការដាក់ទណ្ឌកម្មនោះក្នុងទំហំដែលចាំបាច់សម្រាប់ការអប់រំដល់កូនតែប៉ុណ្ណោះ។[31] ប៉ុន្តែ ប្រសិនបើ អ្នកមានអំណាចមេបា បានដាក់ទណ្ឌកម្មហួសពីកម្រិតនៃចាំបាច់ ដូចជាការដាក់ទណ្ឌកម្មដែលបណ្តាលឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬ ផ្លូវកាយដល់កូនក្នុងនាមជាវិន័យ ដែលមិនត្រូវទទួលបានការអនុញ្ញាត គេអាចប្រកាសព្យួរ ឬ ដកហូតអំណាចមេបានោះបានតាមផ្លូវតុលាការ។[32]

### ឃ. ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម

អនីតិជនអាចធ្វើការប្រកបវិជ្ជាជីវៈ ឬធ្វើអាជីវកម្មបាន លុះត្រាតែមានការអនុញ្ញាតពីអ្នកមានអំណាចមេបា។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការយល់ព្រមពីអ្នកមានអំណាចមេបា កូនមិនអាចប្រកបវិជ្ជាជីវៈ ឬ អាជីវកម្មបានឡើយ ប្រសិនពុំមានការយល់ព្រមពីអ្នកមានអំណាចមេបា ហើយអ្នកមានអំណាចមេបា ក៏អាចកម្រិតនូវការអនុញ្ញាត ឬ ការលុបចោលនូវការអនុញ្ញាតនោះបានដែរ។[33] ហេតុនេះ អ្នកមានអំណាចមេបា អាចលុបចោលសកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រម លើកលែងតែ សកម្មភាពដែលទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ទោះបីជាអ្នកមានអំណាចមេបា មានសិទ្ធិធ្វើសកម្មភាពតំណាងឱ្យកូនក៏ដោយ បើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាពរបស់កូន អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូននោះដែរ។

[31] មាត្រា ១០៤៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[32] មាត្រា ១០៤៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[33] មាត្រា ២០ និងមាត្រា ១០៤៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ខ. ការទាមទារឱ្យប្រគល់កូន

អ្នកមានសិទ្ធិអំណាចមេបាអាចទាមទារឱ្យប្រគល់កូន ពីអ្នកដែលបានដាក់កូនក្នុងស្ថានភាពខុសច្បាប់ ដូចជា កូនត្រូវបានចាប់ពង្រាត់ ឬ កូនត្រូវបានចាប់បង្ខាំងទុកជាដើម ព្រមទាំងករណីបុគ្គលដែលទទួលខុសត្រូវលើកូនជាបណ្តោះអាសន្នតាមរយៈកិច្ចសន្យា ដែលខកខានក្នុងការប្រគល់កូនមកវិញដោយបំពានកិច្ចសន្យា ដោយសារវាជាការរំលោភអំណាចមេបាក្នុងការយកកូនទៅបីបាច់រក្សារូបរាងកាយ និងចិញ្ចឹម។ អ្នកដែលមានអំណាចមេបាអាចទាមទារសំណងការខូចខាតពីតតិយជន ដោយសារការរំលោភលើអំណាចមេបាក្លាយជាអំពើអនីត្យានុកូល ហើយក៏ត្រូវបានអនុញ្ញាតឱ្យសម្រេចសិទ្ធិទាមទារឱ្យប្រគល់កូនតាមរយៈការបង្ខំដោយផ្ទាល់ផងដែរ។

ផ្ទុយទៅវិញប្រសិនបើ អនីតិជនដែលមានសមត្ថភាពខាងឆន្ទៈបន្តរស់នៅជាមួយតតិយជនដោយឆន្ទៈរបស់ខ្លួនផ្ទាល់ នោះមិនមានភាពខុសច្បាប់ឡើយ។ លើសពីនេះ ទៅទៀតប្រសិនបើតតិយជន ត្រូវបានទទួលស្គាល់ថា គាត់កំពុងព្យាយាមការពារកូនពីសភាពការណ៍បន្ទាន់ណាមួយ តតិយជននោះត្រូវបានរួចផុតពីភាពខុសច្បាប់ដែរ។[34]

ដោយឡែក ករណីដែលឪពុកម្តាយបានលែងលះគ្នា ហើយឪពុក ឬ ម្តាយណាម្ខាង ត្រូវបានកំណត់ជាអ្នកដែលមានអំណាចមេបា ប៉ុន្តែ ឪពុក ឬ ម្តាយម្ខាងទៀតមិនព្រមប្រគល់កូន ដូច្នេះ អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬម្តាយ ដែលពុំមានអំណាចមេបាប្រគល់កូន។ ប្រសិនបើអនីតិជនដែលមានសមត្ថភាពខាងឆន្ទៈបន្តរស់នៅជាមួយឪពុក ឬម្តាយដែលមិនមានអំណាចមេបាដោយឆន្ទៈរបស់ខ្លួនផ្ទាល់ ឆន្ទៈរបស់កូនមិនគួរត្រូវបានអើពើទាំងស្រុងទេ ហេតុដូច្នេះ អ្នកដែលមានអំណាចមេបា និង ឪពុក ឬម្តាយដែលពុំមានអំណាចមេបាត្រូវពិភាក្សាគ្នាដើម្បីដោះស្រាយបញ្ហានេះ។[35] ទោះបីជាការសម្រេចសិទ្ធិរបស់អ្នកដែលមានអំណាចមេបាជាការសំខាន់ក៏ដោយ ក៏គួរតែមានការដោះស្រាយបញ្ហា ស្របទៅតាមកាលៈទេសៈដោយផ្តល់អាទិភាពដល់សុខុមាលភាពរបស់កូន។

### ២.១.២. ការគ្រប់គ្រងទ្រព្យសម្បត្តិនិងការតំណាង

អ្នកដែលមានអំណាចមេបា មានសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និងតំណាងឱ្យកូននោះចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិនោះ។ ការតំណាងនេះហៅថា ការតំណាងដែលច្បាប់បានកំណត់។[36] ជាធម្មតា កូនជាអនីតិជនពុំមានទ្រព្យសម្បត្តិច្រើនទេ ទ្រព្យសម្បត្តិដែលអនីតិជនអាចទទួលបាន គឺ

[34] មាត្រា ១០៤៧ កថាខណ្ឌទី១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៥

[35] មាត្រា ១០៤៧ កថាខណ្ឌទី២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៥

[36] មាត្រា ១០៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

តាមរយៈសន្ធិកម្ម ប្រទានកម្ម សំណងនៃការខូចខាតជាអាទិ៍។ ម្យ៉ាងទៀតដោយសារកូនជាអនីតិជន ដែលពុំមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាព ឬថែរក្សា ឬចាត់ចែងទ្រព្យសម្បត្តិ ដោយខ្លួនឯងបានឡើយ ទើបច្បាប់កំណត់ថា អ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ និងតំណាងឱ្យកូន ទាក់ទងនឹងសកម្មភាពទាំងនោះ។

លើសពីនេះ ទោះបីជាអ្នកមានអំណាចមេបា មានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនក៏ដោយ បើទ្រព្យសម្បត្តិដែលអនីតិជនទទួលបានការអនុញ្ញាតឱ្យចាត់ចែង ឬ ប្រកបអាជីវកម្ម ឬ តតិយជនបានផ្តល់ទ្រព្យសម្បត្តិទៅឱ្យកូន ដោយបង្ហាញឆន្ទៈថាមិនឱ្យឪពុកម្តាយណាម្ខាង ឬ ទាំងសងខាងដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិទេ ទ្រព្យសម្បត្តិនោះពុំស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកមានអំណាចមេបាឡើយ។ ទោះបីជាតតិយជនបានបង្ហាញឆន្ទៈដូចខាងលើក៏ដោយ ក៏អនីតិជនមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិដោយខ្លួនឯងបាន ករណីនេះ តតិយជននោះអាចកំណត់អំពីអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបាន។ ប៉ុន្តែ បើពុំបានកំណត់ទេ ឬ ទោះបីជាបានកំណត់ក៏ដោយ កាលបើសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងនោះ ត្រូវរលត់ ឬ មានការចាំបាច់ផ្លាស់ប្តូរ ហើយតតិយជននោះ មិនបានកំណត់អ្នកអនុវត្តគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបាន តាមការទាមទាររបស់កូន ឬ ញាតិក្នុង៤ (បួន)ថ្នាក់របស់កូន ឬ តំណាងអយ្យការ។

ថ្វីបើអ្នកមានអំណាចមេបា មានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនក៏ពិតមែន ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ឬ យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន នូវទ្រព្យសម្បត្តិរបស់កូន សម្រាប់ផលប្រយោជន៍របស់ខ្លួន ឬ របស់តតិយជន ឬ ក្លែងបន្លំធ្វើឱ្យចុះអន់ថយ តាមរយៈការគ្រប់គ្រងមិនស្មោះត្រង់ឡើយ។ ពោលគឺអ្នកមានអំណាចមេបា ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុច្ចរិត។ ក្នុងករណីអ្នកមានអំណាចមេបាធ្វើសកម្មភាពបំពានករណីនេះ គេអាចព្យួរ ឬ ដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបានតាមផ្លូវតុលាការ។

ម្យ៉ាងវិញទៀត អ្នកមានអំណាចមេបា មិនត្រូវធ្វើសកម្មភាពដែលផលប្រយោជន៍របស់ខ្លួន និងកូនផ្ទុយគ្នានោះទេ ដូចជា អ្នកមានអំណាចមេបាទិញអចលនវត្ថុរបស់កូន ឬ ដាក់អចលនវត្ថុរបស់កូនជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនជាអាទិ៍។ ក្នុងករណីដែលអ្នកមានអំណាចមេបា មានបំណងធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬ អាចបណ្តាលឱ្យមានភាពផ្ទុយគ្នានៃផលប្រយោជន៍រវាងខ្លួន និងកូន ដូចនេះ អ្នកមានអំណាចមេបាត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន។ បើពុំដូច្នេះទេ សកម្មភាពដែលអ្នកមានអំណាចមេបាបានប្រព្រឹត្ត គឺជាការតំណាងដែលគ្មានសិទ្ធិ ហើយសកម្មភាពនោះពុំបង្កើតអានុភាពចំពោះកូនទេដែលជាម្ចាស់សិទ្ធិឡើយ។

### ២.១.៣. ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាចំពោះអំពើអនីត្យានុកូលរបស់កូន

អនីតិជន គឺជាជនដែលមានសមត្ថភាពក្នុងការវិនិច្ឆ័យឆន្ទៈមិនគ្រប់គ្រាន់ ហេតុនេះនៅក្រោមគោលការណ៍នៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ប្រសិនបើអនីតិជនបានប្រព្រឹត្តអំពើអនីត្យានុកូល អនីតិជននោះមិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះទេ។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ប៉ុន្តែ ដោយសារអនីតិជន មិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងដើម្បីការពារជនរងគ្រោះដោយសារអំពើដែលអនីតិជនបានប្រព្រឹត្ត ដូច្នេះ ច្បាប់កំណត់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជំនួសអនីតិជន ដែលអ្នកទទួលខុសត្រូវនោះ គឺអ្នកមានករណីយកិច្ចត្រួតពិនិត្យ ដែលក្នុងករណីនេះ ជាអ្នកមានអំណាចមេបា។[37] ប៉ុន្តែ បើកូនមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាត្រូវបានបន្ថយ មានន័យថា អនីតិជនត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់អ្នកដទៃផងដែរ ដោយសារអំពើរបស់ខ្លួន វាគឺជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងអ្នកមានអំណាចមេបានិងកូន។

ផ្ទុយទៅវិញ អ្នកមានអំណាចមេបា អាចរួចផុតអំពីការទទួលខុសត្រូវដោយសាមគ្គីចំពោះសំណងនៃការខូចខាតបាន ប្រសិនបើអាចបញ្ជាក់បានថា ខ្លួនបានបំពេញករណីយកិច្ចជាប្រក្រតី ដូចជា នៅពេលកូនប្រព្រឹត្តអំពើអនីត្យានុកូល កូនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សាលារៀនជាអាទិ៍។ មួយវិញទៀត បើកូនមានទ្រព្យសម្បត្តិតាមរយៈ ប្រទានកម្ម ឬសន្តិកម្ម ហេតុនេះអាចទទួលខុសត្រូវដោយសាមគ្គីជាមួយអ្នកមានអំណាចមេបា។ ប៉ុន្តែ ករណីកូនគ្មានទ្រព្យសម្បត្តិ កូនមិនអាចទទួលខុសត្រូវដោយសាមគ្គីជាមួយអ្នកមានអំណាចមេបាបានឡើយទោះបីជាកូនមានអាយុច្រើនជាង ១៤ (ដប់បួន) ឆ្នាំក៏ដោយ ហើយសម្រាប់ស្ថានភាពនេះផងដែរ អ្នកមានអំណាចមេបានឹងទទួលខុសត្រូវចំពោះសំណងនៃការខូចខាតទាំងស្រុង។

### ២.១.៤. ការផ្តល់ការយល់ព្រមចំពោះទំនាក់ទំនងឋានៈបុគ្គល

អ្នកមានអំណាចមេបា អាចធ្វើការយល់ព្រមលើទំនាក់ទំនងញាតិ ចំពោះកូនជាអនីតិជន។ ក្នុងករណីដែលភាគីម្ខាងក្នុងចំណោមភាគីដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាអនីតិជន អនីតិជននោះចាំបាច់ត្រូវមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។[38] មានន័យថា ដើម្បីឱ្យអាពាហ៍ពិពាហ៍ដែលមានភាគីម្ខាងជាអនីតិជន ដំណើរការទៅបាន ចាំបាច់ណាស់ត្រូវតែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់កូនដែលជាអនីតិជន។

---

[37] មាត្រា៧៤៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា៩៥៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ផ្ទុយទៅវិញ អនីតិជនដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍អាចទាមទារឱ្យតុលាការសម្រេចសេចក្ដីជំនួសការយល់ព្រមនោះបាន ព្រោះតែអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលបដិសេធយល់ព្រមដោយគ្មានមូលហេតុសមរម្យ។[39] ដូច្នេះតុលាការក៏អាចសម្រេចជំនួសឱ្យការបង្ហាញឆន្ទៈយល់ពីអ្នកមានអំណាចមេបា ទោះបីជាការរៀបអាពាហ៍ពិពាហ៍ត្រូវបានបដិសេធពីអ្នកអំណាចមេបា ឬអ្នកអាណាព្យាលក៏ដោយ បើរកឃើញថាការមិនយល់ព្រមនោះ គ្មានហេតុផលសមរម្យក្នុងការអះអាងលើការបដិសេធចំពោះចំណងអាពាហ៍ពិពាហ៍។

## ២.២. សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងអ្នកពុំមានសិទ្ធិអំណាចមេបា

សិទ្ធិ និងករណីយកិច្ចរបស់ឳពុក ឬម្ដាយដែលមិនមែនជាអ្នកដែលមានសិទ្ធិអំណាចមេបា ក្នុងករណីដែលឳពុក ឬម្ដាយម្ខាងទៀតមានអំណាចមេបាទោល ដោយសារឳពុកម្ដាយនោះបានលែងលះគ្នា ឬមិនបានរៀបអាពាហ៍ពិពាហ៍។ ដោយសារតែឳពុក ឬម្ដាយដែលមិនមែនជាអ្នកដែលមានអំណាចមេបា ជាធម្មតា តែងតែមិនស្នាក់នៅជាមួយកូន។ ឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនមានសិទ្ធិ និងករណីយកិច្ចយ៉ាងដូចម្ដេចចំពោះកូន ជាប្រធានបទដែលនឹងបកស្រាយខាងក្រោម។

### ២.២.១. ការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

ឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន អាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ វាគឺជាសិទ្ធិ ហើយជាមួយគ្នា ក៏ជាករណីយកិច្ចរបស់ឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនដែរ។ ម្យ៉ាងវិញទៀត កូនក៏មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនដែរ។ ទោះបីជាឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន មិនមែនជាអ្នកដែលមានអំណាចមេបាក៏ដោយ ដរាបណាគាត់នៅតែជាឳពុក ឬម្ដាយ នោះឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន ចាំបាច់ត្រូវចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនដើម្បីការលូតលាស់ដ៏ប្រសើររបស់កូន។

ផ្ទុយទៅវិញ ប្រសិនបើឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនធ្លាប់បានរំលោភបំពានទៅលើកូនពីអតីតកាល ឬប្រសិនបើការចូលជួប ឬប្រាស្រ័យទាក់ទងនឹងគ្នា មិនបណ្ដោយឱ្យមានផលប្រយោជន៍ដល់សុខុមាលភាពរបស់កូននោះទេ ឳពុក ឬម្ដាយដែលមិនរស់នៅ ជាមួយកូននោះ អាចនឹងត្រូវហាមឃាត់មិនឱ្យទាក់ទងជាមួយនឹងកូន។ សុខុមាលភាពរបស់កូនមាន អាទិភាពជាងបញ្ហាផ្សេងៗទាំងអស់។ ប្រសិនលើការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នាជាមួយឳពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន អាចជួយដល់ការរីកលូតលាស់របស់កូន ការចូលជួប ឬការប្រាស្រ័យ ទាក់ទងគ្នានេះ គួរតែត្រូវបានអនុញ្ញាត រីឯ ប្រសិនបើធ្វើឱ្យមានការ

[39] មាត្រា៩៥៣ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

រាំងស្ទះ ឬអាចនឹងបណ្តាលឱ្យមានការរាំងស្ទះដល់ការរីកលូតលាស់របស់កូន ការចូលជួបនិងការប្រាស្រ័យទាក់ទងគ្នានេះមិនគួរត្រូវបានអនុញ្ញាតឡើយ។

ម្យ៉ាងទៀត ការចូលជួប និងប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានផ្សារភ្ជាប់ជាមួយនឹងការបែងចែកបន្ទុកនៃសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគ្មានការគិតគូរហ្មត់ចត់ឡើយ។ មានន័យថា ទោះបីជាឪពុក ឬម្តាយដែលមិនរស់នៅជាមួយ ពុំបានទទួលបន្ទុកនូវចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូនក៏ដោយ ក៏រឿងនោះមិនត្រូវយកមកធ្វើជាមូលហេតុក្នុងការហាមឃាត់ឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូននោះ មិនឱ្យចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន ឬក្នុងការតម្រូវឱ្យឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូននោះបង់ប្រាក់ចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដើម្បីជាថ្នូរនឹងការយល់ព្រមឱ្យចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូននោះដែរ។ ការចូលជួប និងការប្រាស្រ័យទាក់ទងនេះ មិនត្រូវយកមកប្រើជាមធ្យោបាយក្នុងការចរចាឡើយ។[40]

### ២.២.២. ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាក៏នៅតែជាឪពុក ឬ ម្តាយតាមច្បាប់របស់កូនដែរ។ ម្យ៉ាងទៀត ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូនអាចមានករណីយកិច្ចច្រើន ក្នុងនាមជាឪពុក ឬ ម្តាយ ដូចជាករណីយកិច្ចក្នុងការបង់ការចំណាយលើការចិញ្ចឹមកូនជាដើម។ ដូច្នេះ ការដឹងពីស្ថានភាពកូនដែលមិនរស់នៅជាមួយខ្លួន គឺជាករណីយកិច្ចរបស់ឪពុក ឬ ម្តាយនោះ ដើម្បីធានាឱ្យមានការរីកលូតលាស់បានយ៉ាងល្អរបស់កូន។ ហេតុផលគឺដោយសារថា ការដឹងអំពីស្ថានភាពរបស់កូន គឺជាការដឹងថាតើអ្នកដែលមានអំណាចមេបាទោលបានអនុវត្តអំណាចនេះបានត្រឹមត្រូវដែរឬទេ។[41]

### ២.២.៣. ការពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន

ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កូន និង ដើម្បីឱ្យមានប្រសិទ្ធិភាពនូវសិទ្ធិ និងករណីយកិច្ចរបស់ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាត្រូវតែពិភាក្សាគ្នា អំពីចំណុចដែលបានកំណត់ដូចខាងក្រោម៖

- ការអប់រំកូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់៖ មានន័យក្នុងករណីដែលអ្នកមានអំណាចមេបា បញ្ជូនកូនឱ្យសិក្សាទៅមហាវិទ្យាល័យ ឬក៏ទៅបរទេស ត្រូវការចំណាយច្រើន ដែលប៉ះពាល់ដល់ការការបែងចែកបន្ទុកនៃសោហ៊ុយសម្រាប់ចិញ្ចឹមកូន ហើយការអប់រំនេះគឺជាកត្តាសំខាន់សម្រាប់ជីវិត និងអនាគតរបស់កូន។ ដូច្នេះ ទាមទារឱ្យមានការពិភាក្សាគ្នារវាងឪពុកនិងម្តាយ។

[40] មាត្រា១០៤០ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[41] មាត្រា១០៤១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

- ការផ្លាស់ប្តូរទីសំណាក់របស់កូន ពីរាជធានី ខេត្តមួយ ទៅរាជធានី ខេត្តមួយទៀត៖ ប្រសិនបើកូនផ្លាស់ប្តូរទីសំណាក់ទៅទីឆ្ងាយ ការផ្លាស់ប្តូរនេះអាចបណ្តាលឱ្យមានការលំបាក ឬ ក៏មិនអាចទៅរួចសម្រាប់ឪពុក ឬ ម្តាយដែលមិនរស់នៅជាមួយកូន ក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ហើយមានការលំបាកក្នុងការទទួលសេចក្តីរាយការណ៍អំពីស្ថានភាពរបស់កូន។ ដូច្នេះ ករណីដែលទីសំណាក់របស់កូនត្រូវបានផ្លាស់ប្តូរទៅរាជធានី ខេត្តផ្សេងៗទៀត ក៏ត្រូវបានបញ្ចូលជាចំណុចដែលត្រូវពិភាក្សាដែរ។
- វិជ្ជាជីវៈ ឬអាជីវកម្មរបស់កូន៖ ជាធម្មតា កូនមិនអាចប្រកបវិជ្ជាជីវៈ ឬ អាជីវកម្ម និងទទួលការអប់រំនៅក្នុងសាលាក្នុងពេលជាមួយគ្នាបានទេ។ ហេតុនេះ ប្រសិនបើកូនប្រកបវិជ្ជាជីវៈ ឬ អាជីវកម្ម មានន័យថាកូនមិនទទួលនូវការអប់រំបន្ថែមលើការអប់រំដែលជាកាតព្វកិច្ច ដូច្នេះ ប្រសិនបើកូនដែលជា អនីតិជនប្រកបវិជ្ជាជីវៈ ឬ ធ្វើអាជីវកម្ម អ្នកដែលមានអំណាចមេបាគួរផ្តល់ការអនុញ្ញាតឱ្យកូន ក្រោយពេលមានការពិភាក្សាជាមួយនឹងឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា។
- សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន៖ ក្នុងសកម្មភាពនេះ ទាមទារឱ្យមានការពិភាក្សាគ្នារវាងឪពុក ឬ ម្តាយ។ ប៉ុន្តែ ការពិភាក្សាពុំបាច់ធ្វើឡើយ ប្រសិនបើការព្យាបាលនោះត្រូវធ្វើឡើងជាបន្ទាន់។
- ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន៖ ប្រសិនបើទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិដែលអាចដាក់ទ្រព្យសម្បត្តិរបស់កូនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ នោះចាំបាច់ត្រូវមានការពិគ្រោះយោបល់រវាងអ្នកមានអំណាចមេបា និង អ្នកពុំមានអំណាចមេបា។
- ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និងទ្រព្យសម្បត្តិរបស់កូន៖ ទាមទារឱ្យអ្នកដែលមានអំណាចមេបា និង ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ធ្វើការពិភាក្សាទៅលើចំណុចសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងថែរក្សារូបកាយរបស់កូន និង ទ្រព្យសម្បត្តិរបស់កូន ដូច្នេះប្រសិនបើឪពុក ឬ ម្តាយ គិតថាចំណុចអ្វីមួយគឺជារឿងចាំបាច់សម្រាប់សុខុមាលភាពរបស់កូន ទោះបីជាមាន ឬ គ្មានអំណាចមេបាក៏ដោយ ក៏ឪពុក ឬ ម្តាយនោះ គួរតែស្នើឱ្យមានការពិភាក្សា ហើយឪពុក ឬ ម្តាយម្ខាងទៀតដែលទទួលសំណើ មានករណីយកិច្ចក្នុងការឆ្លើយតបទៅនឹងសំណើនោះដោយស្មោះត្រង់ដែរ។ ដោយពុំចាំបាច់សង្ស័យ ការផ្លាស់ប្តូរនូវឋានៈបុគ្គលរបស់កូន ដូចជាការរៀបអាពាហ៍ពិពាហ៍ ឬ ស្មុំកូន ជាដើម។[42]

[42] មាត្រា១០៤២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

# ជំពូកទី៣
# ការបាត់បង់សិទ្ធិអំណាចមេបា

# ជំពូកទី៣
# ការបាត់បង់សិទ្ធិអំណាចមេបា

## ផ្នែកទី១ ការផ្លាស់ប្តូរអ្នកមានអំណាចមេបា

បើទោះបីជាអំណាចមេបាត្រូវបានកំណត់តាមការសម្រេច នៅពេលមានការលែងលះ ឬ តាមទំនាក់ទំនងរវាងការទទួលស្គាល់ក៏ដោយ ក៏តុលាការអាច ផ្លាស់ប្តូរអ្នកមានអំណាចមេបាបាន តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់របស់កូន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន។[43]

ការផ្លាស់ប្តូរអ្នកមានអំណាចមេបា ជាយន្តការតាមផ្លូវតុលាការមួយដើម្បីសង្គ្រោះកូន ក្នុងករណីដែលអ្នកមានអំណាចមេបា មិនអាចអនុវត្តបានដោយសារមូលហេតុដូចជា៖ ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា (១.១) ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា (១.២) និង ករណីអ្នកមានអំណាចមេបាទទួលមរណភាពជាដើម (១.៣)។

### ១.១. ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា

ក្នុងការអនុវត្តអំណាចមេបា អ្នកមានអំណាចមេបាត្រូវមានករណីយកិច្ចក្នុងការគ្រប់គ្រងកូនដែល ជាអនីតិជនឱ្យបានត្រឹមត្រូវ ដោយការប្រុងប្រយ័ត្ន និងមិនមានការបំពានសិទ្ធិជាអ្នកមានអំណាចមេបា ជាដើម ប៉ុន្តែប្រសិនអ្នកមានអំណាចមេបាធ្វើការគ្រប់គ្រងដោយមានការធ្វេសប្រហែស ឬដោយមានការបំពានសិទ្ធិអំណាចមេបា នាំឱ្យមានការព្យួរ ឬដកហូតអំណាចមេបា។ ចំពោះករណីមានការព្យួរ ឬដកហូត និងការលាឈប់អានុភាពកើតមានឡើងនៅពេលមានសេចក្តីសម្រេចរបស់តុលាការ មានន័យថាអំណាចមេបាដែលធ្លាប់មាននឹងត្រូវបាត់បង់ក្នុងអំឡុងដែលបានកំណត់តាមរយៈខ្លឹមសារនៃសេចក្តីសម្រេច។

#### ១.១.១. ការព្យួរ ឬការដកហូតអំណាចមេបា

ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា បានបំពានសិទ្ធិអំណាចមេបា ឬ ធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានសិទ្ធិអំណាចមេបាដូចជា ការប្រើប្រាស់អំពើហិង្សាទៅកូនដែល បណ្តាលឱ្យទទួលរងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់កូនជាដើម។[44] ជាក់ស្តែង ដូចក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបាបានប្រព្រឹត្តនូវអំពើហិង្សាទៅលើកូន ដែលហិង្សានេះកើតមានដោយសារការញៀនគ្រឿងស្រវឹង ដូច្នេះ អំណាចមេបាត្រូវបានព្យួរ ឬដកហូត។ ប៉ុន្តែ ពេលក្រោយមកបុគ្គលនោះបានជំនះ ដោយការផ្តាច់នូវការញៀនគ្រឿងស្រវឹង ឈប់ប្រើអំពើហិង្សា និងមានការសោកស្តាយចំពោះអ្វីដែល ខ្លួនបានប្រព្រឹត្តកន្លងមក ដែលនាំឱ្យគាត់អាចទទួលបាននូវសិទ្ធិអំណាចមេបាវិញ តាមរយៈការដាក់ពាក្យសុំទៅតុលាការឱ្យលុបចោលការព្យួរ ឬការដកហូតអំណាច

[43] មាត្រា១០៣៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[44] មាត្រា១០៤៨ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មេបា ហើយតុលាការនឹងធ្វើការពិចារណា ដោយវិនិច្ឆ័យជាចម្បងទៅលើការសម្រេចឱ្យបាននូវសុខុមាលភាពរបស់កូន។[45]

ក្រៅពីមូលហេតុជាអំពើហិង្សា អ្នកមានអំណាចមេបាក៏អាចត្រូវបានប្រកាសព្យួរ ឬដកហូត សិទ្ធិអំណាចមេបាផងដែរ ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបាបានធ្វើឱ្យមានការអន្តរាយដល់ ទ្រព្យសម្បត្តិរបស់កូន ដោយសារតែការគ្រប់គ្រងទ្រព្យសម្បត្តិមិនបានត្រឹមត្រូវ ការយកទៅប្រើប្រាស់ និងការដែលយកទ្រព្យសម្បត្តិរបស់កូនមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនជាអាទិ៍។[46] ប៉ុន្តែ ប្រសិនបើមូលហេតុនៃការព្យួរ ឬដកហូតសិទ្ធិអំណាចមេបានៃការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានបញ្ចប់ តុលាការអាចធ្វើការប្រកាសលុបចោលការព្យួរ ឬដកហូត សិទ្ធិអំណាចមេបានៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន តាមការស្នើសុំ របស់សាមីជនដែលត្រូវបានប្រកាសព្យួរ ឬដកហូតសិទ្ធិអំណាចមេបានៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ញាតិក្នុង៤ (បួន)ថ្នាក់របស់ជននោះ។[47]

### **១.១.២. នីតិវិធីនៃការព្យួរ ឬការដកហូតអំណាចមេបា**

ការព្យួរ ឬ ដកហូតអំណាចមេបា គឺជាយន្តការមួយដែលតាមរយៈនោះ តុលាការអាចធ្វើការព្យួរ ឬដកហូតអំណាចមេបាទាំងស្រុងពីអ្នកមានអំណាចមេបា ដោយសេចក្តីសម្រេចរបស់ខ្លួនតាមពាក្យសុំ របស់បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំ ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា បានបំពានសិទ្ធិអំណាចមេបា ឬការធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចជាដើម។ ការព្យួរ ឬដកហូតអំណាចមេបា ត្រូវបាន ធ្វើឡើងតាមរយៈការទាមទាររបស់ញាតិក្នុង៤ (បួន)ថ្នាក់របស់កូន មេឃុំ ឬចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។ តុលាការដែលមានសមត្ថកិច្ច គឺ តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា ហើយការសម្រេចសេចក្តីអំពីពាក្យសុំព្យួរ ឬដកហូត អំណាចមេបាត្រូវបានធ្វើឡើងតាមរយៈដីការសម្រេច។ ដោយឡែក ទោះបីជាតុលាការធ្វើការសម្រេចដកហូតអ្នកមានអំណាចមេបាចំពោះភាគីម្ខាងក៏ពិតមែន ក៏ភាគីម្ខាងទៀតដែលជាអតីតអ្នកមានសិទ្ធិអំណាចមេបាអាចមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបានដដែល តាមខ្លឹមសារនៃដីការសម្រេច។

តាមការអនុវត្តជាក់ស្តែង តុលាការកម្រនឹងទទួលបាននូវពាក្យសុំឱ្យដកហូតអំណាចមេបាណាស់ ហើយបើសិន ជាតុលាការទទួលនូវពាក្យសុំដកហូតអំណាចមេបា ក៏ការសម្រេចបានអំពីការដកហូតអ្នកមានអំណាចមេបាអាចធ្វើទៅបាន លុះត្រាមូលហេតុនៃការដកហូតនោះ បានធានាដល់ ផលប្រយោជន៍របស់កូនជាធំទាក់ទងនឹងការរស់នៅ ការផ្គត់ផ្គង់ ការថែរក្សា ការអប់រំ ស្ថានភាពសេដ្ឋកិច្ច និងស្ថានភាពដែលទាក់ទងនឹងផលប្រយោជន៍កូនផ្សេងៗទៀត។

[45] មាត្រា១០៤៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

[46] មាត្រា១០៦១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[47] មាត្រា១០៦២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ១.២. ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា

ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ជាយន្តការដែលតាមរយៈនោះ តុលាការធ្វើការអនុញ្ញាតឱ្យអ្នកមានអំណាចមេបាទោល (ឪពុក ឬម្ដាយ) លាឈប់ពីការងារធ្វើជាអ្នកមានអំណាចមេបា ឬ អំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិកូនបាន។

### ១.២.១. មូលហេតុនៃការលាឈប់ពីអ្នកមានអំណាចមេបា

កាលបើ មានមូលហេតុមិនអាចជៀសវាងបាន ដូចជាអ្នកមានអំណាចមេបា ជាប់ពន្ធនាគារ ឬ សម្រាកនៅមន្ទីរពេទ្យរយៈពេលវែងជាអាទិ៍ តុលាការអាចអនុញ្ញាតឱ្យមានការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា និងសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន តាមរយៈពាក្យសុំរបស់អ្នកដែលមានអំណាចមេបា។[48] ប៉ុន្តែ ប្រសិនបើ មូលហេតុ នៃការលាឈប់នោះបានបញ្ចប់ អ្នកមានអំណាចមេបាដែលលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ឬសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ អាចទទួលបដិទាននូវអំណាចមេបាមកវិញបានដោយត្រូវទទួលការអនុញ្ញាតពីតុលាការ។[49]

ដែលជាធម្មតា ឪពុកម្ដាយ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា តែករណីបើឪពុក ឬ ម្ដាយណាម្ខាងមានបញ្ហាបាត់បង់សតិជាអាទិ៍ ដែលពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬម្ដាយម្ខាងទៀតត្រូវប្រើប្រាស់អំណាចមេបានោះ។[50] ប៉ុន្តែ ចំពោះករណីមានតែឪពុក ឬម្ដាយដែលជាអ្នក មានអំណាចមេបា (អំណាចមេបាទោល) ហើយកូនបានធ្លាក់ក្នុងស្ថានភាព ដែលពុំមានអ្នកមានអំណាចមេបា ដោយសារតែការព្យួរ ឬដកហូតអំណាចមេបា ឬលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬម្ដាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។[51] ឧទាហរណ៍ ករណី “ក” បានសម្រាលកូនដោយមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ហេតុនេះ “ក” ជាអ្នកមានអំណាចមេបាចំពោះកូនដែលជាអនីតិជន បើទោះបីជាលោក “ខ” ជាឪពុក ធ្វើការទទួលស្គាល់ក៏ដោយ។ តែដោយហេតុ “ក” បានធ្វើការលាឈប់ពីអ្នកមានអំណាចមេបា ដូច្នេះ ក្នុងករណីនេះ តុលាការអាចយក “ខ” ដែលជាឪពុកមកធ្វើជា អ្នកមានអំណាចមេបាបាន។ ចំពោះករណីលែងលះ ប្រសិនឪពុក ឬម្ដាយជាអ្នកមានអំណាចមេបាតាមការពិភាក្សាគ្នា ហើយអ្នកដែលមានអំណាចមេបាទោលនោះ បានទទួលមរណភាព ដែលធ្វើឱ្យកូនពុំមានអ្នកមានអំណាចមេបា នាំឱ្យឪពុក ឬម្ដាយដែលនៅរស់ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកអំណាចមេបាដោយស្វ័យប្រវត្តិ។[52] ករណី

[48] មាត្រា១០៥០ កថាខណ្ឌទី១ និង មាត្រា១០៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] មាត្រា១០៥០ កថាខណ្ឌទី២ និង មាត្រា១០៦៣ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[50] មាត្រា១០៦៣ វាក្យខ័ណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា១០៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[52] មាត្រា១០៥១ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

លែងលះក្រៅពីស្ថានភាពទទួលមរណភាព តុលាការក៏អាចមានការផ្លាស់ប្តូរអ្នកមានអំណាចមេបាបាន តាមការទាមទាររបស់អ្នកមានសិទ្ធិស្នើសុំ កាលបើអ្នកមានអំណាចមេបា ដែលត្រូវបានកំណត់នោះធ្វើឱ្យខូចប្រយោជន៍ដល់កូន ដូចជាការប្រព្រឹត្តអំពើណាមួយដែលមិនសមជាអ្នកមានអំណាចមេបា។[53]

### ១.២.២. នីតិវិធីនៃការលាឈប់

ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ត្រូវបានធ្វើឡើងតាមការដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា ហើយការសម្រេចអំពីពាក្យសុំលាឈប់ពី អ្នកមានអំណាចមេបាត្រូវធ្វើឡើងតាមរយៈដីកាសម្រេច។ បើទោះបីជាឪពុក ឬម្តាយ ដែលបានធ្វើការលាឈប់ពីអ្នកមានអំណាចមេបាក៏ដោយ ក៏គាត់អាចទទួលបាននូវអំណាចមេបាមកវិញដែរ បើមានការអនុញ្ញាតពីតុលាការ។

## ១.៣. ករណីអ្នកមានអំណាចមេបាទទួលមរណភាព

ក្នុងស្ថានភាព ដែលបានកំណត់អ្នកដែលមានអំណាចមេបាតាមការពិភាក្សានៅពេលមានការលែងលះ បើឪពុក ឬម្តាយ ដែលមានអំណាចមេបាទោលចំពោះកូនបានទទួលមរណភាព កូននឹងមិនត្រូវដាក់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជនឡើយ បើឪពុក ឬម្តាយដែលនៅរស់បានក្លាយជា អ្នកមានអំណាចមេបាចំពោះកូន មានន័យថា នៅពេលដែលឪពុក ឬម្តាយដែលជាអ្នកមានអំណាចមេបាបានទទួលមរណភាពនាំឱ្យឪពុក ឬម្តាយ ដែលនៅរស់នោះនឹងត្រូវក្លាយជាអ្នកមានអំណាចមេបាចំពោះកូនដោយស្វ័យប្រវត្តិតាមបញ្ញត្តិច្បាប់។[54]

ផ្ទុយទៅវិញ ប្រសិនបើពុំអាចផ្លាស់ប្តូរអ្នកមានអំណាចមេបាបានទេ ដោយហេតុក្នុងករណី លែងលះបានយកម្តាយ ជាអ្នកមានអំណាចមេបាចំពោះកូន ក្រោយមកម្តាយត្រូវទទួលមរណភាព ហេតុនេះឪពុកជាអ្នកមានអំណាចមេបា ប៉ុន្តែឪពុកបានលាឈប់ធ្វើជាអ្នកមានអំណាចមេបា ដោយសារតែខ្លួនត្រូវមានគ្រួសារក្រោយ (រៀបអាពាហ៍ពិពាហ៍ថ្មី) ដែលបណ្តាយឱ្យកូនធ្លាក់ក្នុងស្ថានភាព ពុំមានអ្នកអនុវត្តអំណាចមេបា ហើយដើម្បីសង្គ្រោះក្នុងករណីនេះ ត្រូវមានការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជននោះ ដើម្បីចិញ្ចឹមបីបាច់ និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជន។ ទោះបីយ៉ាងណាក៏ដោយ មានករណីខ្លះអ្នកមានអំណាចមេបាអាចបីបាច់ថែរក្សារូបកាយកូនបាន ពោលគឺអាចបំពេញករណីយកិច្ច ទាក់ទងនឹងកូនដោយពុំមានបញ្ហាអ្វីនោះទេ តែអ្នកមានអំណាចមេបានោះមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិ កូនបាន ដោយសារមានការព្យួរ ឬដកហូតសិទ្ធិអំណាចនៃ

[53] មាត្រា១០៣៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[54] មាត្រា១០៥១ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការគ្រប់គ្រងទ្រព្យសម្បត្តិ ឬលាឈប់ដែលក្នុងករណីនេះ របបអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវបានចាប់ផ្តើមទេដោយតុលាការនឹងធ្វើការជ្រើសរើសអ្នកតំណាងពិសេសឱ្យកូនដោយឆន្ទានុសិទ្ធិ។

## ផ្នែកទី២ ការបញ្ចប់អំណាចមេបា

ការបញ្ចប់អំណាចមេបា គឺសំដៅទៅដល់ការបញ្ចប់សិទ្ធិ និងករណីយកិច្ចរបស់អ្នកអំណាចមេបា លើការបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ មានន័យថា ឪពុក ឬម្តាយ មិនមានករណីយកិច្ចចិញ្ចឹមបីបាច់ថែរក្សា និងគ្រប់គ្រងកូនបន្តទៀតឡើយ ដោយហេតុថាការកូនបានក្លាយជាបុគ្គលដែលមានសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

### ២.១. ការដល់នីតិភាពរបស់កូន

អំណាចមេបា ត្រូវបញ្ចប់នៅពេលដែលកូនបានដល់នីតិភាព គឺ នៅពេលដែលកូនមានអាយុគ្រប់តាមការកំណត់របស់ច្បាប់ សំដៅដល់នីតិជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព មានន័យថាបុគ្គលដែលជានីតិជនអាចធ្វើការសកម្មភាពដោយឯករាជ្យដោយខ្លួនឯងបាន មិនចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបាទៀតឡើយ។

ជាមួយគ្នានេះដែរ កូនអាចរួចផុតពីអំណាចមេបាបាន ទោះបីជាកូនមិនទាន់គ្រប់អាយុតាមកំណត់របស់ច្បាប់ក៏ដោយ ក្នុងករណីដែលកូនបានទទួលអត្តាធីនភាព គឺក្នុងករណីដែលអនីតិជនដែលបានដល់អាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ មិនចាំបាច់ពឹងពាក់នរណាឡើយ តុលាការអាចប្រកាសនូវអត្តាធីនភាពបាន តាមពាក្យសុំរបស់អនីតិជននោះ[55] ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។ ម្យ៉ាង តុលាការត្រូវសួរយោបល់ពីអ្នកមានអំណាចមេបាផងដែរ។ ដោយអនីតិជនទទួលបានអត្តាធីនភាព មិនចាំបាច់មានការប្រកាសពីតុលាការទេ ផ្អែកលើមូលហេតុអាពាហ៍ពិពាហ៍។[56] អនីតិជនដែលមានគំនិតចាស់ទុំអាចរៀបអាពាហ៍ពិពាហ៍បាន អាចចាត់ទុកជាអនីតិជនម្នាក់ដែលអាចប្រកបកិច្ចការជួញដូរបាន ដូច្នេះត្រូវទទួលបានអត្តាធីនភាព និងរួចផុតពីអំណាចមេបាដើម្បីធានានូវឯករាជ្យភាពនៃអាពាហ៍ពិពាហ៍នោះ។ អត្តាធីនភាព គឺមានអានុភាពអាចធ្វើឱ្យច្បាប់ចាត់ទុកថាអនីតិជននោះបានដល់នីតិភាពហើយ ក្លាយជាជនដែលមានសិទ្ធិដូចនីតិជនដែលមានអាយុគ្រប់ ១៨ ឆ្នាំ និងអាចធ្វើសកម្មភាពបានដូចជានីតិជនផងដែរ។ ដោយសារតែអានុភាពនេះ អនីតិជននោះអាចធ្វើសកម្មភាពពាណិជ្ជកម្ម ដូចជាការបើកអាជីវកម្មផ្ទាល់ខ្លួនដោយមិនចាំបាច់មានការអនុញ្ញាតពីម្តាយឪពុក (អ្នកដែលមានអំណាចមេបា) ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។ អនីតិជន ព្រមទាំងអាចធ្វើ សកម្មភាពតាមកិច្ចសន្យា

[55] មាត្រា២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[56] មត្រា២១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយអាចបង្កើត កែប្រែ និងរំលត់កាតព្វកិច្ចបាន និងអាចធ្វើនូវសកម្មភាពឯកតោភាគីបានថែមទៀត។ លើសពីនេះទៅទៀត អនីតិជនអាចទទួលបាននូវបុគ្គលភាពគតិយុត្ត (ភាពជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច) យ៉ាងពេញលេញទៀតផង។

### ២.២. អានុភាពនៃការបញ្ចប់អំណាចមេបា

នៅពេលដែលអំណាចមេបាបានបញ្ចប់ជាលទ្ធផល ការគ្រប់គ្រងទាក់ទងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិ ក៏ត្រូវបញ្ចប់ដែរ ហើយទាក់ទងនឹងការបញ្ចប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនអ្នកមានអំណាចមេបាត្រូវគណនាចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយគ្មានការយឺតយ៉ាវ (អំឡុងពេលសមរម្យដែលឆ្លើយតបនឹងស្ថានភាពជាក់ស្តែង)។ នៅក្នុងអំឡុងពេលនៃការអនុវត្តអំណាចមេបា អ្នកមានអំណាចមេបា បានចំណាយសោហ៊ុយជាច្រើនទាក់ទងនឹងការចិញ្ចឹមកូន រួមទាំងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ប៉ុន្តែការចិញ្ចឹមកូន គឺជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ហេតុនេះ ពុំសមរម្យឡើយក្នុងការឱ្យកូនបង់សងមកវិញ។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ច្បាប់បានកំណត់ថាបើអ្នកមានអំណាចមេបា បានទទួលចំណូលពីទ្រព្យសម្បត្តិរបស់កូន ត្រូវចាត់ទុកថាជាការទូទាត់នឹងសោហ៊ុយចិញ្ចឹមបីបាច់កូន និងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន។[57] មានន័យថា នៅក្នុងអំឡុងពេលអនុវត្តអំណាចមេបា អ្នកមានអំណាចមេបា អាចអាស្រ័យផលពីទ្រព្យសម្បត្តិរបស់កូនបាន គឺផលដែលទទួលបានពីទ្រព្យសម្បត្តិនោះ ដូចជា ថ្លៃឈ្នួល ជាអាទិ៍ អ្នកមានអំណាចមេបាមិនចាំបាច់ប្រគល់ឱ្យកូននៅពេលដែលកូនដល់នីតិភាពទេ។ ផ្ទុយទៅវិញ ចំពោះទ្រព្យសម្បត្តិបានផ្តល់មកពីប្រទានកម្ម ហើយអ្នកផ្តល់ឱ្យនោះ បានបង្ហាញឆន្ទៈមិនឱ្យអ្នកមានអំណាចមេបាអាស្រ័យផលពីទ្រព្យសម្បត្តិនោះ ដូចនេះ អ្នកមានអំណាចមេបា មិនអាចអាស្រ័យផលពីទ្រព្យសម្បត្តិនោះបានឡើយ មានន័យថា ចំណូលដែលទទួលបានពីទ្រព្យសម្បត្តិរបស់កូន ត្រូវប្រគល់ឱ្យកូននៅពេលដែលកូនមាននីតិភាព។

ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកមានអំណាចមេបា បានចាត់ចែងលក់ទ្រព្យសម្បត្តិរបស់កូនជាអាទិ៍ នៅពេលដែលកូនមាននីតិភាព ប្រាក់ដែលបានមកពីការលក់នេះ ត្រូវប្រគល់ឱ្យកូន ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាមិនបានប្រគល់ប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិរបស់កូនទេ កូនមានសិទ្ធិទាមទារឱ្យអ្នកមានអំណាចមេបាប្រគល់ ដែលអំឡុងពេលនៃការទាមទារនោះគឺ ៣ (បី) ឆ្នាំគិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់។[58] ក្នុងករណីសិទ្ធិអំណាច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំទាន់មានអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាច

[57] មាត្រា ១០៦៥ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ១០៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មេបាថ្មី) អំឡុងពេលនៃការទាមទារគឺ ៣ (បី) ឆ្នាំគិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានកាន់តំណែង។[59]

## ២.៣. ការអនុវត្តនៃការបញ្ចប់អំណាចមេបា

នៅក្នុងការអនុវត្តនៃការបញ្ចប់អំណាចមេបាត្រូវបានអនុវត្តដូចអាណាត្តិដែរ។ ព្រោះអ្នកគ្រប់គ្រងមានករណីយកិច្ចសង្គ្រោះបន្ទាន់ មានន័យថា បើទោះបីជាអំណាចមេបាត្រូវបានបញ្ចប់ដោយសារតែកូនបានដល់នីតិភាព ឬសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានព្យួរ ឬដកហូតក៏ដោយ ក៏អ្នកមានអំណាចមេបានៅតែបន្តគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដដែល រហូតដល់កូន ឬអ្នកគ្រប់គ្រងថ្មីមានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងសម្បត្តិនោះ ពោលគឺទ្រព្យសម្បត្តិនឹងស្ថិតនៅក្នុងហានិភ័យ បើអ្នកមានអំណាចមេបាលែងគ្រប់គ្រងទ្រព្យសម្បត្តិភ្លាមៗ មុនពេលដែលកូន ឬអ្នកគ្រប់គ្រងថ្មី មានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិ។[60]

ថ្វីត្បិតតែអំណាចមេបាត្រូវបានបញ្ចប់ដោយសារតែកូនដល់នីតិភាពក៏ពិតមែន ក៏មិនប្រាកដថាកូនអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ ឬ កិច្ចការមួយចំនួនដោយឯកឯងបាននោះដែរ ព្រោះកិច្ចការគ្រប់គ្រងទ្រព្យសម្បត្តិមួយចំនួនកន្លងមកជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ដែលកូនមិនបានធ្វើសកម្មភាពគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះពីមុនមកទេ ជាហេតុនាំឱ្យកូនមិនអាចមានលទ្ធភាពក្នុងការគ្រប់គ្រងចាត់ចែងបានភ្លាមៗ។ ដូច្នេះ ប្រសិនបើមានការបញ្ចប់អំណាចមេបា ហើយអ្នកមានអំណាចមេបាធ្វើការបញ្ចប់លើការគ្រប់គ្រងទ្រព្យសម្បត្តិភ្លាមៗ ប្រាកដណាស់ទ្រព្យសម្បត្តិដែលគាត់ធ្លាប់ធ្វើការគ្រប់គ្រងនោះនឹងត្រូវរងការខូចខាត ដែលកើតឡើងដោយហេតុការណ៍ណាមួយដែលមិនអាចព្យាករណ៍បាន ដោយហេតុថាក្នុងអំឡុងពេលនោះកូនមិនអាចយល់ដឹងអំពីរបៀបនៃការគ្រប់គ្រងជាដើម។ ការអនុវត្តនេះ នឹងត្រូវអនុវត្តដូចគ្នាផងដែរ ក្នុងករណីមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មី ដោយមូលហេតុមានការព្យួរ ឬដកហូតអ្នកគ្រប់គ្រងទ្រព្យសម្បត្តិគឺអ្នកដែលមានអំណាចមេបាមិនអាចធ្វើការបញ្ចប់ការគ្រប់គ្រងភ្លាមៗ បានឡើយ។

[59] មាត្រា ១០៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[60] មាត្រា ១០៥៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបានបកស្រាយយ៉ាងលំអិតទាក់ទងនឹងប្រធានបទស្តីពីការកំណត់អំណាចមេបាក្នុងរឿងលែងលះរួចមក យើងមើលឃើញប្រធានបទមួយនេះពិតជាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ការកំណត់ឱ្យបានអំពីអ្នកមានអំណាចមេបានៅពេលមានការលែងលះ ជាយន្តការ មួយដ៏សំខាន់សម្រាប់កូនដែលជាអនីតិជន និងដើម្បីជាការធានាដល់កុមារ មានន័យថា បើទោះបី ជាឪពុកម្តាយ ត្រូវបានបែកបាក់ ចែកផ្លូវគ្នាក៏ដោយ ក៏កូននៅតែត្រូវបានទទួលការមើលថែ គ្រប់គ្រង អប់រំ យកចិត្តទុកដាក់ពីឪពុក ឬម្តាយណាម្ខាងដែលបានអនុវត្តន៍អំណាចមេបាទោលចំពោះខ្លួន។ ហើយការកំណត់អំពីអំណាចមេបានៅពេល លែងលះនេះផងដែរ ត្រូវបានធ្វើឡើងស្របពេលជាមួយគ្នានឹងការលែងលះ មិនអាចធ្វើការលែងលះហើយទើបធ្វើការកំណត់អំណាចមេបាតាមក្រោយនោះទេ ដែលការលែងលះតាមការពាក្យសុំ ភាគីនៃពាក្យសុំត្រូវធ្វើការព្រមព្រៀងគ្នាអំពីអំណាចមេបាជាមុនទើបអាចធ្វើការលែងលះតាមការព្រមព្រៀងបាន។ ចំណែកឯ ការលែងលះតាមពាក្យបណ្តឹងវិញ ការកំណត់អំណាចមេបា ត្រូវបានឡើងតាមការទាមទាររបស់ដើមចោទ ឬ ប្រសិនបើ ភាគីមិនអាចពិភាក្សាគ្នាបានអំពីអំណាចមេបាទេ នាំឱ្យការកំណត់អំណាចមេបាត្រូវធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់តុលាការដោយតុលាការនឹងធ្វើការសម្រេច ស្របទៅតាមផលប្រយោជន៍របស់កូនជាធំ។ ក្រោយពីបានធ្វើការកំណត់អ្នកមានអំណាចមេបា តាមរយៈសេចក្តីសម្រេចរួច អ្នកដែលទទួលសិទ្ធិអំណាចមេបាចំពោះកូនត្រូវទទួលសិទ្ធិ និងករណីយកិច្ច ចំពោះកូនតែឯកឯង រីឯអ្នកដែល គ្មានសិទ្ធិអំណាចមេបាក៏ទទួលបានសិទ្ធិ និងករណីយកិច្ចមួយចំនួនផងដែរ តាមអ្វីដែលភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នា ដូចមានកំណត់ក្នុងសេចក្តីសម្រេចបញ្ជាប់ជាដើម។

សរុបជារួមមក នៅពេលមានការលែងលះ ត្រូវកំណត់ឱ្យបានអំពីអ្នកមានសិទ្ធិអំណាចមេបា ដើម្បីធានាដល់ការរស់នៅរបស់កូន ព្រោះថាឪពុកម្តាយ ត្រូវរស់នៅបែកគ្នា ចំណែកកូនត្រូវបានរស់នៅក្រោមការគ្រប់គ្រងមើលថែរបស់ឪពុក ឬម្តាយតែម្ខាង ប៉ុណ្ណោះ ដូច្នេះ ប្រាកដណាស់ កូននឹងត្រូវរស់នៅដោយខ្វះភាពកក់ក្តៅពីឪពុក ឬ ម្តាយម្ខាងទៀត។ ដូចនេះហើយ ប្រសិនបើមានការលែងលះ ការសម្រេចឱ្យបានអំពីអ្នកមានសិទ្ធិអំណាចមេបាសម្រាប់កូន ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឱ្យកូនបានរស់នៅជាមួយអ្នកដែលអាចធ្វើការចិញ្ចឹមបីបាច់ មើលថែឱ្យបានល្អ ម្យ៉ាង ការដែលកំណត់អំពីអំណាចមេបាដ៏ល្អមួយសម្រាប់កូន គឺជាការយន្តការមួយដ៏សំខាន់ ព្រោះមិនសូវជាជះឥទ្ធិពលអាក្រក់ខ្លាំងដល់ផ្លូវចិត្តរបស់កូន និងមិនប៉ះពាល់ខ្លាំងដល់ប្រយោជន៍កូនក្រោយពីឪពុកម្តាយត្រូវបានផ្តាច់នូវចំណងអាពាហ៍ពិពាហ៍។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានបញ្ចប់ការសរសេរ និងរៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមកឃើញថា ការអនុវត្តច្បាប់ទាក់ទងទៅនឹងការកំណត់អំណាចមេបាក្នុងរឿងលែងលះនៅកម្ពុជា គឺមានភាពខ្វះចន្លោះនៅឡើយដែលជាមូលហេតុនាំឱ្យមានបញ្ហាប្រឈមនៃការលែងលះនិងការកំណត់អំណាចមេបាកើតឡើង។

ជាចុងក្រោយបំផុត យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម ក្នុងគោលបំណង និងឆន្ទៈ ដើម្បីធ្វើឱ្យស្នាដៃមួយនេះ អាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ សមស្របទៅនឹងស្ថានភាពនិងកាលៈទេសៈជាក់ស្តែង ក៏ដូចជាកាត់បន្ថយការលែងលះក្នុងសង្គម។

- មន្ត្រីអត្រានុកូលដ្ឋាន ឃុំ-សង្កាត់ គួរតែបន្តពង្រឹងទៅលើការផ្សះផ្សាគូភាគី ដែលមានបំណងលែងលះគ្នានោះឱ្យមានការត្រូវរ៉ូវគ្នាវិញ។
- ចំណែកឯដំណាក់កាលផ្សះផ្សានៅតុលាការវិញ តុលាការ គួរតែរិះរកគ្រប់មធ្យោបាយដែលពាក់ព័ន្ធនឹងការផ្សះផ្សាលើគូភាគី ដែលចង់ធ្វើការលែងលះ ដើម្បីឱ្យងាកមកប្តូរចិត្តឈប់ចង់ធ្វើការលែងលះ ហើយងាកមករស់នៅជាមួយគ្នាជាប្តីប្រពន្ធធម្មតា។ ជាពិសេសតុលាការគួរតែ ពិចារណាឱ្យបានដិតដល់លើបញ្ហាឧត្តមប្រយោជន៍របស់កូនជាសំខាន់ ដោយមូលហេតុថាបន្ទាប់ពីការលែងលះ ច្បាស់ណាស់ប្រាកដជាកូនក្លាយជាជនរងគ្រោះ ព្រោះត្រូវរស់នៅកំព្រាឪពុក ឬម្តាយ។
- ចំពោះប្តីប្រពន្ធ ដើម្បីកុំឱ្យមានការកើតឡើងនៃការលែងលះ និងដើម្បីឱ្យគ្រួសារមានសុភមង្គល គឺលុះត្រាតែភាគីប្តីប្រពន្ធគួរពិចារណាឱ្យបានត្រឹមត្រូវ គួរតែរស់នៅដោយភាពយោគយល់គ្នា ប្តីត្រូវបំពេញកាតព្វកិច្ចជាប្តីល្អ ប្រពន្ធត្រូវបំពេញកាតព្វកិច្ចជាប្រពន្ធល្អ ត្រូវចេះសហការគ្នា សង្គ្រោះគ្នាទៅវិញទៅមកដូចដែលមានចែងក្នុងច្បាប់ បំពេញឱ្យបានគ្រប់ជ្រុងជ្រោយ នោះគ្រួសារនឹងជួបសុខសុភមង្គល។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងអនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១
- ច្បាប់ស្តីពីរឿងរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩

## ២. សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

- សៀវភៅពន្យល់អំពីក្រមរដ្ឋប្បវេណី
- សៀវភៅសេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
- ឯកសារវិភាគទានច្បាប់ វគ្គសិក្សាច្បាប់សារធាតុ និងច្បាប់នីតិវិធី II មេរៀនទី ៣៖ ការកំណត់អំពីអ្នកមានអំណាចមេបាក្រោយពេលលែងលះ

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** នីតិវិធីនៃការដាក់ពាក្យលែងលះតាមការព្រមព្រៀង

- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង
- ដីកាសម្រេច

**ឧបសម្ព័ន្ធទី២៖** នីតិវិធីនៃការដាក់ពាក្យលែងលះតាមពាក្យបណ្តឹង

- ពាក្យបណ្តឹងលែងលះ
- ដីកាកោះចុងចម្លើយ
- ដីកាកោះដើមចោទ
- ដីកាបញ្ជូន
- កំណត់ហេតុស្តីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី
- សាលក្រម
- លិខិតបញ្ជាក់សាលក្រមស្ថាពរ
- រូបមន្តអនុវត្តសាលក្រម

# ឧបសម្ព័ន្ធទី១
# នីតិវិធីនៃការដាក់ពាក្យលៃខលះ
# តាមការព្រមព្រៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ដីកាកោះ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

<table>
<tr><td colspan="2">បង្គាប់មកចុងចម្លើយឈ្មោះ ................ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។</td></tr>
<tr><td>សញ្ញាណនៃរឿងក្ដី (លេខ និងភាគី)</td><td>សំណុំរឿងក្ដីរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី០៧ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្ដីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៩០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>ធ្វើនៅរតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>ចៅក្រម</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ដីកាកោះ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី

<table>
<tr><td colspan="2">បង្គាប់មកឈ្មោះ ................ ជាដើមចោទ ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៦៤/២០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០២០<br>ដើមចោទឈ្មោះ ................ ចុងចម្លើយ: ................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០២០ វេលាម៉ោង៨:០០ ព្រឹក<br>មន្ទីរស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៩០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៩៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃព្រហស្បតិ៍ ៩ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣<br>រតនគិរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

*សំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹង*
*លេខ.........................*

**កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូង**

*បានឃើញមាត្រា១១៣ ដល់មាត្រា១២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។*

*សញ្ញាណរឿងក្តី*

*ប្តឹងសុំតុលាការអនុវត្តដោយបង្ខំដូចខាងក្រោម*

***១. សុំលែងលះរវាងពីប្តីឈ្មោះ* ..................... *និងប្រពន្ធឈ្មោះ* ...................... ។**

***២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ* ...................... *ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ* ...................... ។**

*លោក ................. ប្រធាននិងចៅក្រមសាលាដំបូងខេត្តរតនគិរី*

*លោក ..................... ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី*

***អ្នកដាក់ពាក្យសុំឈ្មោះ*** ...................... *ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ភាគីម្ខាងទៀតឈ្មោះ*** .................. *ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្ទិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។*

***ឆ្នាំពីរពាន់មួយម្ភៃ ខែឧសភា ថ្ងៃទីប្រាំពីរ វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក*** *នៅសាលាដំបូងខេត្តរតនគិរី បានធ្វើនីតិវិធីផ្សះផ្សារដល់គូភាគីដើម្បីឲ្យបានរស់នៅជាប្តីប្រពន្ធនិងគ្នាវិញ ប៉ុន្តែគូភាគីនៅតែមិនអាចរស់នៅជាមួយគ្នាបាន ហេតុនេះតុលាការបញ្ឈប់នីតិវិធីផ្សះផ្សារ ដោយបន្តនីតិវិធីបញ្ជាក់ដំបូងរវាងអ្នកដាក់ពាក្យសុំឈ្មោះ* .................. *ជាមួយនិងភាគីម្ខាងទៀតឈ្មោះ* ............. ។

*-អ្នកដាក់ពាក្យសុំឈ្មោះ ................................ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅសាលាសង្កាត់បឹងកន្សែង។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍នាងខ្ញុំមានកូនចំនួន១នាក់ ។ នាងខ្ញុំសុំសិទ្ធគ្រប់គ្រង ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុល នាងខ្ញុំនិងប្តីបានព្រមព្រៀងគ្នារួចរាល់*

*អស់ហើយ សុំឲ្យលោកចៅក្រម ទទួលស្គាល់ការព្រមព្រៀងនេះផង មានក្នុងកំណត់ហេតុ ផ្សះផ្សាសម្របសម្រួលលេខ ២៤/០១,០៤,២០១៩ ។*

*មកដល់ដំណាក់កាលនេះ នាងខ្ញុំអស់មនោសញ្ចេតនានិងគ្នាហើយ នាងខ្ញុំបានធ្វើកិច្ចព្រមព្រៀងលែងលះ ជាមួយភាគីប្តី បន្ទាប់មកបានដាក់ពាក្យសុំឲ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀង និងសុំសិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់។*

*-ភាគីម្ខាងទៀតឈ្មោះ ................ បានធ្វើសេចក្តីថ្លែងការណ៍តបថាៈ ខ្ញុំបាទឯកភាពតាមសេចក្តីថ្លែងការណ៍របស់ភាគីអ្នកដាក់ពាក្យសុំ ដោយយល់ព្រមលែងលះពីប្រពន្ធឈ្មោះ ........................ និងយល់ព្រមប្រគល់កូនចំនួន១នាក់ឲ្យទៅអ្នកដាក់ពាក្យសុំ។ ចំពោះទ្រព្យសម្បត្តិរួម និងប្រាក់បំណុលរួបខ្ញុំបាទនិងប្រពន្ធបានព្រមព្រៀងគ្នារួចរាល់អស់ហើយ។*

*រីឯប្រាក់អាហារកិច្ចសុំបង់ជូនក្នុងមួយខែៗ ចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) រហូតដល់កូនធំពេញវ័យ ។*

*-អ្នកដាក់ពាក្យសុំឈ្មោះ ........................ បានធ្វើសេចក្តីថ្លែងការណ៍ថាៈ នាងខ្ញុំឯកភាព ចំពោះសេចក្តីថ្លែងការណ៍របស់ភាគីប្តី ដោយមិនមានសំណូមពរអ្វីទៀតនោះឡើយ។*

***យើងបានបញ្ចប់សេចក្តីបញ្ជាក់ដំបូង នៅវេលាម៉ោងដប់មួយ ព្រឹកថ្ងៃខែឆ្នាំដដែល។***

***បានអានកំណត់ហេតុនៃនីតិវិធីនៃសេចក្តីបញ្ជាក់ដំបូងជូនភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត ធ្វើយថាត្រឹមត្រូវសូមផ្តិតមេដៃទុកជាកស្តុតាង ។***

| **អ្នកដាក់ពាក្យសុំ** | **ភាគីម្ខាងទៀត** | **ក្រឡាបញ្ជី** | **ចៅក្រម** |
|---|---|---|---|
| | | | |
| ...................... | ...................... | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណីមិនមែន
បណ្តឹងលេខ..............................
ដីកាសម្រេចលេខៈ ............ /២០

**ដីកាសម្រេច**

យើង ............... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

អមដោយលោក ................. ជាក្រឡាបញ្ជី

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នសខែ ០៦ ចុះថ្ងៃទី ០២១/០៧០១/រកម/កក្កដា ឆ្នាំ២០០៦។

-បានបញ្ចប់នីតិវិធីបញ្ជាក់ដំបូងនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីមិនមែនជាបណ្តឹងលេខ០៦៤ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។

**រវាង**

អ្នកដាក់ពាក្យសុំឈ្មោះ .................. ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

**នឹង**

ភាគីម្ខាងទៀតឈ្មោះ ............. ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកឯកជន មានទីលំនៅភូមិអូរកន្តិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី។

កម្មវត្ថុនៃបណ្តឹង

១. សុំលែងលះរវាងពីប្តីឈ្មោះ ............. និងប្រពន្ធឈ្មោះ ................. ។

២. ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួន១នាក់ឈ្មោះ ........ ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ................. ។

បានឃើញកំណត់ហេតុស្តីពីសេចក្តីបញ្ជាក់ដំបូងចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ រវាងអ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ ................ ដោយភាគីទាំងពីរ ស្នើសុំឲ្យតុលាការចេញដីកាសម្រេចតាមពាក្យសុំរបស់ខ្លួនដោយលែងលះតាមការព្រមព្រៀង។

**យល់ឃើញថា**

១-ពាក្យសុំចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អ្នកដាក់ពាក្យសុំឈ្មោះ .................... និងភាគីម្ខាងទៀតឈ្មោះ .............. ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- នៅតំណាក់កាលនៃនីតិវិធីបញ្ជាក់ដំបូង តុលាការបានព្យាយាមធ្វើការផ្សះផ្សារួចហើយ ប៉ុន្តែគូភាគីនៅតែមិនព្រមសះជានឹងគ្នាវិញទេ ដោយគូភាគីនៅតែស្នើសុំឲ្យតុលាការ សម្រេចលែងលះឲ្យខ្លួនដដែល។ គប្បីតុលាការលើកយកការស្នើសុំរបស់ភាគីទាំងពីរមកពិចារណា។

៣-គូភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៣៧ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ នៅសាលាសង្កាត់ បឹងកន្សែង ក្រុងបានលុង បញ្ជាក់ថា គូភាគីគឺពិតជាមានអាពាហ៍ពិពាហ៍ស្របច្បាប់ប្រាកដមែន។ ដូចនេះដើម្បីចៀសវាងបញ្ហាផ្សេងៗកើតឡើងជាយថាហេតុ គប្បីតុលាការសម្រេចឲ្យលែងលះរវាងគូភាគីតាមការព្រមព្រៀង។

៤-នៅក្នុងនីតិវិធីបញ្ជាក់ដំបូង ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

ក-លែងលះជាប្តី-ប្រពន្ធ

ខ-ប្រគល់សិទ្ធិគ្រប់គ្រងកូនចំនួនមួយនាក់ឈ្មោះ .................... ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ .................. ជាម្តាយអ្នកគ្រប់គ្រង។

៥- តាមបញ្ញត្តិមាត្រា៤៧ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីកាតព្វកិច្ចរបស់មាតាបិតា ក្នុងការរួមគ្នាចិញ្ចឹមបីបាច់ ថែរក្សាកូនឲ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គម និងមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី (ការសម្រេចអំពីអ្នកមានអំណាចមេបា) គប្បីគូភាគី រួមគ្នាបំពេញកាតព្វកិច្ចរបស់ខ្លួនតាមបញ្ញត្តិច្បាប់។

៦-ដោយសម្ព័ន្ធភាពជីវិតអាពាហ៍ពិពាហ៍របស់អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានធ្វើឲ្យសហព័ទ្ធម្ខាងៗទទួលរងសម្ពាធផ្លូវចិត្តធ្វើឲ្យផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបានឡើយ។ គប្បីតុលាការលើកយកការស្នើសុំ និងការព្រមព្រៀងគ្នារបស់ភាគីតាមនីតិវិធីបញ្ជាក់ដំបូង មកសម្រេចដោយយោងតាមបញ្ញត្តិមាត្រា៩៧៨ និងមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៧-ភាគីនៃអាពាហ៍ពិពាហ៍ មានបំណងពិតប្រាកដក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍ គប្បីតុលាការទទួលយកមកពិចារណា និងសម្រេចតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

៨-ទ្រព្យសម្បត្តិរួមនិងប្រាក់បំណុល នៅក្នុងកំណត់ហេតុនៃនីតិវិធី សេចក្តីបញ្ជាក់ដំបូង ភាគីអ្នកដាក់ពាក្យសុំឈ្មោះ ...................... និងភាគីម្ខាងទៀតឈ្មោះ .................... បានបញ្ជាក់ថាខ្លួនបានព្រមព្រៀងគ្នារួចរាល់អស់ហើយ ចំណុចនេះមិនគប្បីតុលាការលើកមកធ្វើការពិចារណានោះឡើយ ។

៩-នៅក្នុងដំណាក់កាលនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតបានឯកភាពគ្នាក្នុងការបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូន ក្នុងមួយខែៗចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) គប្បីតុលាការសម្រេចតាមការព្រមព្រៀង ។

ជាការសន្និដ្ឋាន គប្បីសម្រេចលែងលះរវាងអ្នកដាក់ពាក្យសុំឈ្មោះ ..................... និងភាគីម្ខាងទៀតឈ្មោះ .................. តាមពាក្យសុំលែងលះតាមការព្រមព្រៀងរបស់ភាគី ទៅតាមបញ្ញត្តិមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

**ហេតុដូច្នេះសម្រេច**

ក/-ឲ្យអ្នកដាក់ពាក្យសុំឈ្មោះ .................. និងភាគីម្ខាងទៀតឈ្មោះ ................ ផ្តាច់សមគ្គសង្វាសតាមការព្រមព្រៀងរបស់គូភាគី មាត្រា ៧៧៨ និងមាត្រា ៧៧៩ នៃក្រមរដ្ឋប្បវេណី។

ខ/-ប្រគល់សិទ្ធិចិញ្ចឹម បីបាច់ ថែរក្សាកូនចំនួនមួយនាក់ឈ្មោះ .................. ភេទស្រី កើតថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៧ ឲ្យទៅអ្នកដាក់ពាក្យសុំឈ្មោះ ................... ជាម្តាយជាអ្នកមានអំណាចមេបាតាមមាត្រា ៤៧ រដ្ឋធម្មនុញ្ញ និង មាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

គ/-ភាគីដែលមិនបានគ្រប់គ្រង ថែរក្សាកូន មានសិទ្ធិទៅសួរសុខទុក្ខកូនបានគ្រប់ពេលវេលាតាមមាត្រា ១០៣៨ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលគ្រប់គ្រងថែរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលឲ្យភាគីម្ខាងទៀតបានបំពេញកិច្ចការនេះ។

ឃ/-បង្គាប់មកឈ្មោះ ................. បង់ប្រាក់អាហារកិច្ចចំនួន ១៥០,០០០ រៀល (មួយរយហាសិបពាន់រៀល) សម្រាប់ចិញ្ចឹមកូនរហូតដល់ធំពេញវ័យជូនទៅអ្នកស្រី ជឿន ច័ន្ទលីដា ក្នុងមួយខែៗ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ ។

ង/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំដែលបានបង់រួច។

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

..............................

---

**បានឃើញនិងឯកភាព**

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ប្រធានសាលាដំបូង**

បានចម្លងតាមច្បាប់ដើម

ថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរីថ្ងៃទី ,១៥ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធទី២
# នីតិវិធីនៃការដាក់ពាក្យលែងលះ
# តាមពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹងលែងលះ

**ដើមចោទ៖** ឈ្មោះ ....................... ភេទស្រី អាយុ ៣០ ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ មានទីលំនៅបច្ចុប្បន្នភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី លេខទូរស័ព្ទ ០៩៧ ៦៩ ៣២ ០០៦។

**ចុងចម្លើយ៖** ឈ្មោះ .................. ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរធ្វើចំការ មានទីលំនៅបច្ចុប្បន្នជា ទណ្ឌិត (នៅក្នុងពន្ធនាគារខេត្តរតនគិរី) ។

**សូមគោរពជូន**
**លោក ប្រធាន សាលាដំបូងខេត្តរតនគិរី**

**សូមទានជ្រាប!**

**តាមរយៈ៖** លោកប្រធានលេខាធិការដ្ឋានសាលាដំបូងខេត្តរតនគិរី

**កម្មវត្ថុ៖** សុំប្តឹងឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម

-លែងលះប្តីឈ្មោះ .....................

-សុំសិទ្ធគ្រប់គ្រងកូន ប្រុស ស្រី ចំនួន ០២ នាក់

អង្គហេតុ មូលហេតុចាំបាច់បញ្ជាក់អំពីការទាមទារ

តបតាមអង្គហេតុ មូលហេតុ និងកម្មវត្ថុខាងលើនាងខ្ញុំសូមគោរពជម្រាបជូនលោក **ប្រធាន** មេត្តាជ្រាបថា៖ នាងខ្ញុំបានរួមរស់ជាមួយ និងភាគីប្តី ក្នុងឆ្នាំ ២០១៧ តាមប្រពៃណី ដោយមិនមានការបញ្ជាក់ និងចុះសំបុត្រអាពាហ៍ពិពាហ៍អ្វីឡើយ មានតែប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ តែប៉ុណ្ណោះ។

រយះពេលរួមរស់និងគ្នាក្នុងគ្រួសារ មិនមានការគោរពសិទ្ធគ្នាជាប្តីប្រពន្ធ និងចុងក្រោយនេះភាគីប្តីបានប្រើប្រាស់គ្រឿងញៀន ត្រូវបានតុលាការផ្តន្ទាទោសតាមផ្លូវច្បាប់ ។

ដើម្បីជៀសវាងបញ្ហាផ្សេងៗដែលកើតមានក្នុងគ្រួសារតទៅទៀត នាងខ្ញុំសុំដាក់ពាក្យបណ្តឹងមកលោក ប្រធាន សុំចេញសាលក្រមតាមកម្មវត្ថុខាងលើ ដើម្បីបានបញ្ចប់បញ្ហាគ្រួសារដោយសន្តិវិធីតាមច្បាប់ ។

**ភស្តុតាងបញ្ជាក់**

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍

-សៀវភៅគ្រួសារ

-សៀវភៅស្នាក់នៅ

-សំបុត្របញ្ជាក់កំណើត កូនស្រីឈ្មោះ .......................

-សំបុត្របញ្ជាក់កំណើត កូនប្រុសឈ្មោះ ........................

-អត្តសញ្ញាណប័ណ្ណ ០១ សន្លឹក

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមលោក **ប្រធាន** មេត្តាទទួលពាក្យបណ្តឹងរបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូមលោក **ប្រធាន** មេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ៕

ថ្ងៃ សុក្រ ៧ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅរតនគិរី,ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

**ស្នាមមេដៃស្តាំ**

..........................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកចុងចម្លើយឈ្មោះ .......... ភេទប្រុស អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។ មានលេខទូរស័ព្ទ៖ ០៣១ ៦៦៦៦ ៥២៨</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ...................... ចុងចម្លើយ: ......................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល ☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៥០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br><br>ថ្ងៃ............................ ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី............ ខែ មិថុនា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**បញ្ជាក់**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងរដ្ឋប្បវេណី

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកដើមចោទឈ្មោះ ............. ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគរ។ មានលេខទូរស័ព្ទ៖ ០៩៧ ៧៦០ ៥៤ ៩៣</td></tr>
<tr><td>សញ្ញាណនៃរឿងក្តី (លេខ និងភាគី)</td><td>សំណុំរឿងក្តីរដ្ឋប្បវេណីលេខ ៧៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០<br>ដើមចោទឈ្មោះ ................. ចុងចម្លើយ: ........................</td></tr>
<tr><td>កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបង្ហាញខ្លួន</td><td>ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក<br>បន្ទប់ស៊ើបសួរទី១ នៃសាលាដំបូងខេត្តរតនគិរី</td></tr>
<tr><td>ប្រភេទដំណាក់កាលនៃនីតិវិធី (សូមគូស☐ លើលេខ នៃនីតិវិធីដែលចាំបាច់)</td><td>១-ការផ្សះផ្សា ☑ ២-នីតិវិធីត្រៀមសំរាប់ការទាញហេតុផល☑<br>៣-ការប្រកាសសាលក្រម☐ ៤-ការទាញហេតុផលដោយផ្ទាល់មាត់ ☐</td></tr>
<tr><td>ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ<br>(សូមសរសេរបញ្ជាក់ឈ្មោះឯកសារបើចាំបាច់ឲ្យមកកាន់)</td><td></td></tr>
<tr><td>ទណ្ឌកម្មជាអាទ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ</td><td>១-ចំពោះសាមីភាគី: បើពុំចូលខ្លួន នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ តាមមាត្រា១៥០ កថាខណ្ឌ២ និងមាត្រា២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។<br>២-ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួន ៣.៥៩៩$ (បីពាន់បួនរយកៅសិបប្រាំបួនដុល្លាអាមេរិក)។ តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។</td></tr>
<tr><td colspan="2">សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។<br>ថ្ងៃ............................... ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤<br>ធ្វើនៅរតនគិរី, ថ្ងៃទី...............ខែមិថុនា ឆ្នាំ២០២០<br>**ចៅក្រម**</td></tr>
</table>

**<u>បញ្ជាក់</u>**

-ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបានសូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុ នោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តរតនគិរី**

លេខ ................./២០

# ដីកាបញ្ជូន

## ផ្ញើជូន
## លោក អធិការនៃអធិការដ្ឋាននគរបាលស្រុកអូរយ៉ាដាវ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | គោលដៅ |
|---|---|---|---|
| ០១ | -ដីកាកោះ ដើមបណ្តឹង<br>ឈ្មោះ ........................ | ០២ ច្បាប់ | ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្តន៍។ |
| ០២ | -ដីកាកោះ ចុងចម្លើយ<br>ឈ្មោះ ........................ | ០២ ច្បាប់ | |
| | | | |
| | សរុបចំនួន | ០៤ច្បាប់ | |

ថ្ងៃ.............................. ឆ្នាំជេស្ឋ ទោស័ក ព.ស២៥៦៤

ធ្វើនៅរតនគិរី,ថ្ងៃទី............ ខែមិថុនា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

**បានទទួល**

ធ្វើនៅរតនគិរី,ថ្ងៃទី................ខែឧសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ.............................

## កំណត់ហេតុស្តីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

## សញ្ញាណរឿងក្តី

ប្តឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្តាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្តី ។

លោក .................... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ដើមបណ្តឹងឈ្មោះ ................. ភេទស្រី អាយុ ៣៧ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ អាជីវករគ្រប់គ្រងរថយន្តដឹកអ្នកដំណើរ លេខទូរស័ព្ទ ០៩៧ ៧៦០ ៤៥ ៩៣ មានមេធាវីតំណាងដោយអណត្តិ ........................ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងប្រាំបួន និងសូន្យ១នាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ដើមបណ្តឹងឈ្មោះ .................... បានឆ្លើយបញ្ជាក់ថា នាងខ្ញុំសុំអោយ លោកចៅក្រម ចេញសេចក្តីសម្រេច តាមពាក្យបណ្តឹងរបស់នាងខ្ញុំ ចុះថ្ងៃទី៣១.០៥.២០២០ ក្នុងការលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ដោយមូលហេតុ នាងខ្ញុំនឹងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបសម្រេចចិត្តលែងលះគ្នាតាមផ្លូវច្បាប់ ហើយក្នុងពេលនេះ ប្តីនាងខ្ញុំក៏បានព្រមព្រៀងតាមពាក្យបណ្តឹងនេះដែរ ។

**ស.ឆ** មេធាវី លោក ........... បានឆ្លើយបញ្ជាក់ថា កូនក្តីរបស់ខ្ញុំបាទពិតជារស់នៅមិនចុះសម្រុងជាមួយនឹងភាគីប្តី ហើយមានបញ្ហាក្នុងគ្រួសារគ្រប់បែបយ៉ាង ទើបមកពឹងពាក់រូបខ្ញុំបាទជាមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការ ដោយសុំលែងលះ បែងចែកទ្រព្យរួម សងបំណុល និងសិទ្ធិគ្រប់គ្រងកូន ហើយភាគីប្តីក៏បានព្រមព្រៀងគ្នា ហេតុនេះសុំឲ្យលោកចៅក្រម សម្រេចសេចក្តីតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក បានអានអោយដើមបណ្តឹង មេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ដើមបណ្តឹង** **មេធាវី**

.......................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

សំណុំរឿងរដ្ឋប្បវេណី
លេខ.........................

## កំណត់ហេតុស្តីពីនីតិវិធីត្រៀម
## សម្រាប់ការទាយហេតុផល

បានឃើញមាត្រា១០៩,១១០,១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាស់ឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០១/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

### សញ្ញាណរឿងក្តី

ប្តឹងសុំឲ្យតុលាការចេញសាលក្រមមានដូចខាងក្រោម៖

១. សុំផ្តាច់ នីតិសង្វាសឈប់រួមរស់ជាមួយគ្នា រំលាយសំបុត្រអាពាហ៍ពិពាហ៍ ០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនៅក្នុងក្រុមហ៊ុន និងទទួលខុសត្រូវលើបំណុលទាំងអស់ ។

៤. ប្រគល់ដីលំនៅដ្ឋានចំនួន ០២កន្លែង និងរថយន្តចំនួន ០១គ្រឿង ជូនទៅភាគីប្តី ។

លោក .................... ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តរតនគិរី

លោក ........................ ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

ចុងចម្លើយឈ្មោះ ...................... ភេទ ប្រុស អាយុ ៤១ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានអាស័យដ្ឋានបច្ចុប្បន្នភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី មុខរបរ មន្ត្រីកងរាជអាវុធហត្ថ លេខទូស័ព្ទ ០៣១ ៦៦៦ ៦៥ ២៨ ។

**ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ និងសូន្យៗនាទីព្រឹក** នៅសាលាដំបូងខេត្តរតនគិរី

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនឯកភាពតាមការលើកឡើងរបស់ដើមបណ្តឹង និងការបញ្ជាក់របស់លោកមេធាវី ដើម្បីបានបញ្ចប់បញ្ហាគ្រួសារតាមច្បាប់ដោយសន្តិវិធី ។

**ស.ឆ** ចំពោះទ្រព្យសម្បត្តិរួម ប្រាក់បំណុល ឯកភាពតាមពាក្យបណ្តឹង ចំពោះកូនមានចំនួន ០២នាក់ ឯកភាពប្រគល់ជូនភាគីប្រពន្ធតាមការស្នើសុំ តែខ្លួនសុំសិទ្ធិទំនាក់ទំនង និងសួរសុខទុក្ខកូន ហេតុនេះ សុំលោក ចៅក្រម ចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុនៃនីតិវិធីសេចក្តីបញ្ជាក់ដំបូងនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោងដប់ និងសាមសិបនាទីព្រឹក បានអានអោយចុងចម្លើយស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

**ចៅក្រម** **ក្រឡាបញ្ជី** **ចុងចម្លើយ**

--------------------

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**
**មន្ទីរស៊ើបសួរ ទី១**

## កំណត់ហេតុស្ដីពីនីតិវិធីសាកសួរសាម៉ីភាគី

(មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

| | |
|---|---|
| សញ្ញាណរឿងក្ដី | បណ្ដឹងលេខ ...... ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០<br>បណ្ដឹងលែងលះជានីតិសង្វាស |
| កាលបរិច្ឆេទ | ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០<br>វេលាម៉ោងប្រាំបួន និងសូន្យៗនាទីព្រឹក |
| កន្លែងបើក/បិទ | **សាលាដំបូងខេត្តរតនគិរី** |
| ចៅក្រម | លោក ........................ |
| ក្រឡាបញ្ជី | លោក ........................ |
| ភាគីដែលបានបង្ហាញខ្លួន | -ដើមបណ្ដឹងឈ្មោះ .................... ភេទស្រី អាយុ ៣៧ ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៏ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។<br>-ចុងចម្លើយឈ្មោះ ........................ ភេទប្រុស អាយុ ៤១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៏ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ |

### សេចក្ដីថ្លែងការណ៍របស់ភាគីមានដូចខាងក្រោមៈ

**ស.ឆ ៖** ភាគីដើមបណ្ដឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំឲ្យ លោកចៅក្រម ចេញសាលក្រម មានខ្លឹមសារដូចខាងក្រោមៈ

១. សុំផ្ដាច់នីតិសង្វាសពីភាគីប្ដី និងរំលាយសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ។

២. សុំសិទ្ធិគ្រប់គ្រងកូនចំនួន ០២ នាក់

- ឈ្មោះ ........................ ភេទ ស្រី អាយុ ១៤ឆ្នាំ
- ឈ្មោះ ........................ ភេទ ប្រុស អាយុ ១១ឆ្នាំ

៣. សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមាន

- គ្រប់គ្រងក្រុមហ៊ុន និងរថយន្តដឹកអ្នកដំណើរគ្រប់សាខាទាំងអស់ ឈ្មោះ រតនសម្បត្តិ
- ប្រព័ន្ធលេខទូរស័ព្ទគ្រប់លេខទាំងអស់ប្រើប្រាស់ក្នុងក្រុមហ៊ុនសព្វថ្ងៃ
- ទទួលវ៉ាប់រងសងបំណុលធនាគារអេស៊ីលីដា ចំនួន ៤៥ម៉ឺនដុល្លារអាមេរិក

- បំណុលបុគ្គលផ្សេងៗមានចំនួន ៣៥ម៉ឺនដុល្លារអាមេរិក
- សុំសិទ្ធិគ្រប់គ្រងដីចំនួន ០២កន្លែង
  ១. ដីស្ថិតនៅយាយទូលចេក មានទំហំ ៤០មx៤០ម ស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី
  ២. ដីផ្លូវទៅយក្ខឡោម មានទំហំ ១២មx២៥ម ស្ថិតនៅភូមិភ្នំ សង្កាត់យក្ខឡោម ក្រុងបានលុង ខេត្តរតនគិរី ។

ដោយមូលហេតុថានាងខ្ញុំ និងប្តី រស់នៅមិនចុះសម្រុងនឹងគ្នា ទើបនាងខ្ញុំសម្រេចចិត្ត ពឹងសុំឲ្យ លោកមេធាវី ដាក់ពាក្យបណ្តឹងមកតុលាការដើម្បីបញ្ចប់ការលែងលះ បែងចែកទ្រព្យ សងបំណុល និងសិទ្ធិគ្រប់គ្រងកូន តាមផ្លូវច្បាប់ ។

**ស.ឆ** ក្នុងការលែងលះនេះ នាងខ្ញុំសុំប្រគល់ទ្រព្យសម្បត្តិជូនភាគីប្តីដូចខាងក្រោមៈ
- រថយន្ត ០១គ្រឿង ម៉ាក TOYOTA REALLY ពណ៌ស ផលិតឆ្នាំ២០២០ ផ្លាកលេខ : ភ្នំពេញ BH.9973 ។
- ផ្ទះល្វែង ០១ល្វែង ស្ថិតនៅ **បុរី លឹម ប៊ុណ្ណា** ភូមិអភិវឌ្ឍន៍ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

**ស.ឆ** ចុងចម្លើយ បានឆ្លើយបញ្ជាក់ថា ខ្លួនយល់ព្រមលែងលះ និងទទួលយកទ្រព្យសម្បត្តិពីដើមបណ្តឹង ដែលបានផ្តល់ជូន និងផ្តល់សិទ្ធិអំណាចមេបាលើកូន ជូនភាគីប្រពន្ធ តែខ្លួនសុំសិទ្ធិទំនាក់ទំនងសួរសុខទុក្ខ ។ ហេតុនេះសុំ លោកចៅក្រម ចេញសេចក្តីសម្រេចតាមផ្លូវច្បាប់ ដោយខ្ញុំបាទយល់ព្រមទទួលយកគ្រប់បែបយ៉ាង ។

**ស.ឆ** មេធាវី របស់ដើមបណ្តឹង បានឆ្លើយបញ្ជាក់ថា ខ្លួនសុំអោយលោកចៅក្រមចេញសេចក្តីសម្រេចជូនកូនក្តីរបស់ខ្ញុំបាទ តាមការលើកឡើងខាងលើ ដោយហេតុថា ភាគីប្តីប្រពន្ធ មានគោលបំណង និងឆន្ទៈ លែងលះគ្នាយ៉ាងពិតប្រាកដ ។ ម្យ៉ាងវិញទៀត កូនក្តីរបស់ខ្ញុំបាទ និងចុងចម្លើយ បានឯកភាពគ្នាលើការបែងចែកទ្រព្យ សងបំណុល សិទ្ធិគ្រប់គ្រងកូន រួចរាល់អស់ហើយ ហេតុនេះ សុំ លោកចៅក្រម សម្រេចតាមផ្លូវច្បាប់ ។

បញ្ឈប់កំណត់ហេតុស្តីពីនីតិវិធីសាកសួរសាម៉ីភាគី ដោយមានការឯកភាពគ្រប់ចំណុច ។

ឈប់សួរ អានឲ្យសាម៉ីភាគី និងមេធាវី ស្តាប់ ឆ្លើយថាត្រឹមត្រូវ សូមផ្តិតមេដៃទុកជាភស្តុតាង ។

| **ចៅក្រម** | **ក្រឡាបញ្ជី** | **មេធាវី** | **ដើមបណ្តឹង** | **ចុងចម្លើយ** |
|---|---|---|---|---|
| | | | .................... | .................... |

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងរដ្ឋប្បវេណីលេខ .........
ចុះថ្ងៃទី ខែ ឆ្នាំ
**សាលក្រមលេខ:**
ចុះថ្ងៃទី ខែ ឆ្នាំ

*តាងនាមប្រជារាស្ត្រខ្មែរ*
**សាលាដំបូងខេត្តកណ្ដាល**
បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់
នៅថ្ងៃទី ខែ ឆ្នាំ
ដោយមានសមាសភាព:
-លោក **ជួន ខណ្ណៈ** ចៅក្រម
-លោក **ឃី អៀង** ក្រឡាបញ្ជី

-ដើមចោទឈ្មោះ ........................ ភេទ ........ កើតនៅឆ្នាំ .......... ជនជាតិខ្មែរ មុខរបរកស៊ីបុគ្គលិកក្រុមហ៊ុន អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

-មានលោក ........... ជាមេធាវីតំណាងដោយអាណត្តិ ។

ចុងចម្លើយឈ្មោះ .......... ភេទ .... កីតនៅឆ្នាំ ........ ជនជាតិខ្មែរ មុខរប មេផ្ទះ អាសយដ្ឋាននៅផ្ទះលេខ៦២E0 ផ្លូវលេខ ២(បុរីពិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

១-*<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:</u>*

១-សុំលែងលះពីប្រពន្ធឈ្មោះ ......... ។

២-សុំសិទ្ធិគ្រប់គ្រងកូនៈ

២.១.ឈ្មោះ .................. ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

២.២.ឈ្មោះ ...................... ភេទ .... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-បែងចែកទ្រព្យសម្បត្តិរួមមាន:ដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ជាពីរចំណែកស្មើគ្នា។

៤-*<u>ការពន្យល់ត្រួសៗអំពីរឿងក្ដី:</u>*

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍កាលពីឆ្នាំ ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ: ...... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ........ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ............... ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍អ្នកទាំងពីររស់នៅជាមួយគ្នាមានកូនចំនួន ០២នាក់ មានឈ្មោះ .................. ភេទ .... កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ...................... ភេទ ....... កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

ប៉ុន្តែក្រោយពេលដែល មានកូន ០២ នាក់ អ្នកទាំងពីរតែងតែមានភាពរកាំរកូសជាមួយគ្នាជាញឹកញាប់ ការរស់នៅមិនចុះសម្រុងគ្នា និងបានបែកលំនៅសង្វាសអស់មួយរយៈមកហើយ ជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្ដី ប្រពន្ធតទៅមុខទៀត។ ហើយក៏បានសម្រេចចិត្តដាក់ពាក្យបណ្ដឹងមកតុលាការ ។

៣-*<u>ការអះអាងរបស់ភាគី</u>*:

-ដើមចោទឈ្មោះ .................................. បានអះអាងថា: ខ្លួនប្ដឹងសុំឲ្យតុលាការចេញសាលក្រម ដូចការទាមទារខាងលើ ដោយហេតុថា ខ្លួនបានរៀបការជាមួយឈ្មោះ .................. កាលពីថ្ងៃទី ខែ ឆ្នាំ និងបានទៅចុះ សំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ។ ការរួមរស់នៅជាមួយគ្នាមានកូនចំនួន ០២ នាក់ គឺឈ្មោះ ................. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦ និងឈ្មោះ ...................... ភេទប្រុស កើតថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៤។ ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............. ឃុំ .............. ស្រុក ............. ខេត្ត ............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ០៩.០២.២០១២ និងបានឃើញនិងបញ្ជាក់លេខ:០១៤/១២ ចុះថ្ងៃទី ខែ ឆ្នាំ របស់មេឃុំអូរបាក់រទេះ និងផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ......... ............................ ចុះថ្ងៃទី ...... ខែ ......... ឆ្នាំ ......... ដែលកំពុងបង់រំលោះនៅធនាគារបានចំនួន ១០ខែ ស្មើទឹកប្រាក់ចំនួន ........................................ ដុល្លាអាមេរិក និងមានគ្រឿងអលង្ការសរុបស្មើទឹកប្រាក់ចំនួន ............................ ដុល្លាអាមេរិក សូមបញ្ជាក់ថា ពួកខ្លួនពុំមានជំពាក់បំណុលគេទេ ហើយដីខាងលើក៏ពុំមានជាប់ពាក់ព័ន្ធនឹងការធានាបំណុលគេដែរ ។

-ចុងចម្លើយឈ្មោះ ............. បានចូលមកធ្វើសេចក្ដីថ្លែងការណ៍តបថា: ខ្លួនឯកភាពក្នុងការលែងលះ សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់ សុំប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងពីតនាក់ក្នុងមួយខែចំនួន ៣០០$(បីរយ) ក្នុងករណីកូនទាំងពីរនាក់រស់នៅជាមួយខ្លួន និងទទួលស្គាល់ថាមានទ្រព្យសម្បត្តិរួមដូចការលើកឡើងរបស់ដើមចោទប្រាកដមែន។

ក្រោយការផ្សះផ្សាសម្រុះសម្រួលរួចមកគូរភាគីបានឯកភាពគ្នាដូចខាងក្រោម៖

-ចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ ១៥០០ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............. ឃុំអូរ ............... ស្រុក .................... ខេត្ត ..................... ដែលមានលិខិតលក់ទិញចុះថ្ងៃទី ............................. និងបានឃើញនិងបញ្ជាក់លេខ: ........... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ........ របស់មេឃុំ ................. នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្ដោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ........................................ ......... ចុះថ្ងៃទី ... ខែ ...... ឆ្នាំ ...... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់រាហារកិច្ចចិញ្ចឹមកូន។

-កូនទីមួយឈ្មោះ ................................ ភេទប្រុស និងកូនទីពីរឈ្មោះ ............................ ភេទប្រុស ទុកសិទ្ធិឲ្យកូនគាត់ស្រេចចិត្តដោយខ្លួនគាត់។

-មេធាវីការពារសិទ្ធិដើមចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-មេធាវីការពារសិទ្ធិចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា: សូមតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-*ចំណុចវិវាទ:* ការលែងលះ និងសិទ្ធិគ្រប់គ្រងកូន។

៥-*ចំណុចគ្មានវិវាទ*: ឯកភាពលើការបែងចែកទ្រព្យសម្បត្តិរួម។

## សំអាងហេតុ

១-តាមការអះអាងរបស់គូភាគីឃើញថា ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីកាលពីថ្ងៃទី ..... ខែ ........ ឆ្នាំ ........ និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់បឹងកេងកង២ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ........ នៃសៀវភៅអាពាហ៍ពិពាហ៍លេខ ................ ។ ដូច្នេះឃើញថា ដើមចោទ និងចុងចម្លើយ បានបំពេញករណីយកិច្ចជាប្តីប្រពន្ធស្របច្បាប់ ចំពោះការទាមទារសុំលែងលះនេះតុលាការអាចពិចារណាសម្រេចបាន។ តុលាការបានសាកល្បងធ្វើការផ្សះផ្សាគូភាគីរួចហើយ ប៉ុន្តែគូភាគីនៅតែទាមទារលែងលះគ្នា ដោយសារអស់មនោសញ្ចេតនា អាណិតស្រលាញ់គ្នាជាប្តីប្រពន្ធទៀតហើយ ។

២-នៅក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន ០២នាក់មាន ៖

.ឈ្មោះ ............... ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

.ឈ្មោះ ..................... ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

៣-ទ្រព្យសម្បត្តិរួមមាន៖

-ទ្រព្យសម្បត្តិរួមចំពោះទ្រព្យសម្បត្តិរួមមានដីដីទំហំ .......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............ ឃុំ ............ ស្រុក ............ ខេត្ត ............ ដែលមានលិខិតលក់ទិញចុះថ្ងៃទី .............................. និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី ..... ខែ ... ឆ្នាំ របស់មេឃុំ ............................ នោះខ្លួនសុខចិត្តប្រគល់ឲ្យកូនទាំងពីរគ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

-ផ្ទះកំពុងបង់រំលោះនៅធនាគារមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ................................ ........ ចុះថ្ងៃទី ... ខែ ..... ឆ្នាំ ..... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

-ឯកភាពលើប្រាក់អាហារកិច្ចចិញ្ចឹមកូន។

គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

៤-កូនទីមួយឈ្មោះ ..................... ភេទប្រុស បានសុំរស់នៅជាមួយម្តាយ និងកូនទីពីរឈ្មោះ ..... ............ ភេទប្រុស បានសុំរស់នៅជាមួយឪពុក គប្បីតុលាការសម្រេចតាមការណ៏ស្នើសុំ។

យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ។ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឪពុក ឬម្តាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នាមានសិទ្ធិ

ចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូន" ។

៥-ចំពោះប្រាក់ប្រដាប់ក្តីតុលាការគប្បីឲ្យដើមចោទ និងចុងចម្លើយ ទទួលបន្ទុកម្នាក់ពាក់កណ្តាល (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី )។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ ...................... លែងលះពីចុងចម្លើយឈ្មោះ ........... ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅ៖

២.១.ដើមចោទឈ្មោះ .................. លើកូនឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៤ ។

២.២.ចុងចម្លើយឈ្មោះ ......... លើកូនឈ្មោះ .................. ភេទប្រុស កើតថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦។

ទុកសិទ្ធិឲ្យភាគីដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូន និងផ្តល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៣-ប្រគល់ទ្រព្យសម្បត្តិរួមមាន៖

៣.១-ដីទំហំ ......... ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ............. ឃុំ ............... ស្រុក ................ ខេត្ត ............. ដែលមានលិខិតលក់ទិញចុះថ្ងៃទី ...................... និងបានឃើញនិងបញ្ជាក់លេខ: .......... ចុះថ្ងៃទី .... ខែ ឆ្នាំ ...... របស់មេឃុំ ........... ប្រគល់ឲ្យកូនទាំងពីរនាក់គ្រប់គ្រងចាត់ចែងជាសហកម្មសិទ្ធនៅពេលកូនមាននីតិភាព តែគូរភាគីគ្រប់គ្រងដីនោះជាបណ្តោះអាសន្ន។

៣.២-គ្រឿងអលង្ការទាំងអស់ប្រគល់ឲ្យចុងចម្លើយគ្រប់គ្រងជាកម្មសិទ្ធិទាំងអស់។

៣.៣-ផ្ទះមួយកន្លែងដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ........................... ....... ចុះថ្ងៃទី .. ខែ .... ឆ្នាំ .... ប្រគល់ឲ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា **ជួន ចណ្ណារ៉ា**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ធ្វើនៅខេត្តកណ្តាល,ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ ២០២០

បានឃើញ

**ចៅក្រម**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
លេខ: ...... /២០២០

## លិខិតបញ្ជាក់សាលក្រមស្ថាពរ

យើង **ឃី អៀង** ក្រឡាបញ្ជីនៃសាលដំបូងខេត្តកណ្ដាល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ...... ចុះថ្ងៃទី ...... ខែ ... ឆ្នាំ ........ របស់សាលាដំបូងខេត្តកណ្ដាល។

បានឃើញ សាលក្រមលេខ: ........ ចុះថ្ងៃថ្ងៃទី ... ខែ ... ឆ្នាំ ....... របស់សាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំបញ្ជាក់ការចូលជាសាលក្រមស្ថាពរនៃសាលក្រម ចុះថ្ងៃទី ........ ខែ ...... ឆ្នាំ ....... របស់មេធាវីឈ្មោះ .................... ជាមេធាវីតំណាងដោយអាណត្តិរបស់ឲ្យចុងចម្លើយ។

សូមបញ្ជាក់ថា សាលក្រមលេខ: ........ ចុះថ្ងៃទី ... ខែ ឆ្នាំ ....... របស់សាលាដំបូងខេត្តកណ្ដាល បានចូលជាស្ថាពរពីថ្ងៃទី ...... ខែ ... ឆ្នាំ ........ តទៅហើយដោយភាគីពុំបានប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

យើងចេញលិខិតបញ្ជាក់នេះ ដើម្បីអនុញ្ញាតឲ្យដាក់រូបមន្តអនុវត្តលើសាលក្រមនេះ សម្រាប់ភាគីសុំយកទៅអនុវត្តតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៣
ខេត្តកណ្ដាល , ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**

ឃី . អៀង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

លេខ: /២០២០

## រូបមន្តអនុវត្តសាលក្រម

យើង **ឃី អៀង** ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ មាត្រា ៣៥៤,៣៥៥ និងមាត្រា៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បានឃើញ លិខិតបញ្ជាក់សាលក្រមស្ថាពរលេខ: ចុះថ្ងៃទី ... ខែ ......... ឆ្នាំ របស់ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ពាក្យសុំចុះថ្ងៃទី ... ខែ ......... ឆ្នាំ ......... របស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ .................... ។

**សូមបញ្ជាក់ពីខ្លឹមសារអនុវត្តដូចខាងក្រោម:**

-ម្ចាស់បំណុល នៃការអនុវត្តឈ្មោះ .................... ភេទ ..... កើតនៅឆ្នាំ ......... អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី) ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-កូនបំណុលនៃការអនុវត្តឈ្មោះ .......... ភេទ ... កើតនៅឆ្នាំ ......... អាសយដ្ឋានផ្ទះលេខ៦២E0 ផ្លូវលេខ២(បុរីភិភពថ្មី)ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-អនុវត្តតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ..... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ..... របស់សាលាដំបូងខេត្តកណ្ដាល ដែលបានចូលជាស្ថាពរពីថ្ងៃទី ... ខែ ... ឆ្នាំ ......... គ្រប់ចំណុចទាំងមូលនៃសាលក្រម។

*សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្ត សាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍ អនុវត្តសាលក្រមនេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។*

ថ្ងៃព្រហស្បតិ៍ ០១ ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្ដាល ,ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

ឃី . អៀង